សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# មជ្ឈ្យត្តការពាណិជ្ជកម្មនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


ស្រាវជ្រាវដោយៈ

និស្សិតឈ្មោះ  កញ្ញា **លឹម រ័ត្នធីតា**

សាស្ត្រាចារ្យណែនាំ

**លោក ម៉ៅ បុណ្ណា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៥ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

## សេចក្ដីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ លឹម រ័ត្នធីតា ជានិស្សិតនៃសាលកវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលនឹងត្រូវបញ្ចប់ការសិក្សានាឆ្នាំ២០២០។

### សូមគោរពប្រណិប័តន៍ និងសេចក្ដីកត្តញ្ញូតាធម៌ចំពោះ

លោកឪពុក និងអ្នកម្ដាយ

ដែលលោកបានផ្ដល់កំណើតដល់កូន និងបានលះបង់នូវកម្លាំងកាយ ព្រមទាំងកម្លាំងចិត្តពុះពាររាល់ឧបសគ្គគ្រប់បែបយ៉ាងមិនខ្លាចនឿយហត់ ដោយខិតខំចិញ្ចឹមបីបាច់ថែរក្សា អប់រំ ទូន្មានប្រៀនប្រដៅ និងឧបត្ថម្ភគ្រប់បែបយ៉ាង ដូចជាផ្ដល់ជំនួយ និងការគាំទ្រទាំងផ្នែកស្មារតី និងទ្រព្យសម្បត្តិដើម្បីឱ្យកូនបានសិក្សារៀនសូត្រចាប់តាំងពីកុមារភាព និងបានបន្តការសិក្សារហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រនាពេលបច្ចុប្បន្ន។ កូនសូមលំឱនកាយគោរពជូនពរ លោកឪពុក អ្នកម្ដាយ ឱ្យជួបតែសេចក្ដីសុខ និងជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

### សូមគោរពដឹងគុណ

### ជូនចំពោះ

### សាស្ត្រាចារ្យគ្រប់មុខវិជ្ជា

នាងខ្ញុំ សូមថ្លែងនូវការគោរពដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្ដមសាកលវិទ្យាធិការ** សាកលវិទ្យាធិការរង លោកព្រឹទ្ធបុរស លោកព្រឹទ្ធបុរសរង និងលោក លោកស្រីសាស្ត្រាចារ្យនៃ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** គ្រប់មុខវិជ្ជាទាំងអស់ ដែលបានខិតខំប្រឹងប្រែងបង្ហាត់បង្រៀននាងខ្ញុំ អស់ពីកម្លាំងកាយចិត្ត ដែលបានផ្ទេរចំណេះដឹង និងដំបូន្មានល្អៗ។

ជាពិសេស សូមគោរពថ្លែងអំណរគុណ លោកសាស្ត្រាចារ្យ **ម៉ៅ ម៉ុណ្ណា** ដែលជាសាស្ត្រាចារ្យទទួលបន្ទុក ណែនាំសរសេរសារណានេះ លោកបានជួយតម្រែតម្រង់ទិស ក្នុងការស្វែងរកឯកសារ និងផ្ដល់ឯកសារមួយចំនួន ដែលជាផ្លូវក្នុងការសរសេរប្រធានបទនេះ ព្រមទាំងផ្ដល់គំនិត អប់រំទូន្មាន និងទស្សនៈល្អៗដល់នាងខ្ញុំ ដែលនាំឱ្យការសរសេរសារណានេះកាន់តែប្រសើរឡើង។

ជាចុងក្រោយនាងខ្ញុំ សូមគោរពជូនពរលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ ទាំងអស់ឱ្យជួបតែសេចក្ដីសុខ និងជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

សារណាដែលមានចំណងជើងថា **មជ្ឈត្តការពាណិជ្ជកម្មនៅកម្ពុជា** គឺជាលទ្ធផលដែលនាងខ្ញុំចងក្រងឡើងដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញនីតិសាស្ត្របន្ទាប់ពីបានសិក្សាអស់រយៈ៤ឆ្នាំនៅ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**។ ស្នាដៃស្រាវជ្រាវមួយច្បាប់នេះត្រូវបានស្រាវជ្រាវឡើងក្នុងគោលបំណងបង្ហាញបរិបទនៃមជ្ឈត្តការពាណិជ្ជកម្មនៅប្រទេសកម្ពុជា ដើម្បីចែករំលែកការយល់ដឹងប្រធានបទនេះឱ្យមានការយល់ដឹងកាន់តែទូលំទូលាយថែមទៀត។

នាងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាកម្រងស្នាដៃនៃការស្រាវជ្រាវនេះនឹងរួមចំណែកក្នុងការចែករំលែកចំណេះដឹងដល់សិស្សានុសិស្ស និងមិត្តអ្នកអានទាំងអស់ បានសិក្សាស្វែងយល់បន្ថែមទៀត ដើម្បីចូលរួមអភិវឌ្ឍធនធានមនុស្ស ក្នុងវិស័យច្បាប់ ពាណិជ្ជកម្ម ដូចជាការចែករំលែកចំណេះដឹងពីតួនាទីដ៏សំខាន់របស់មជ្ឈត្តការក្នុងការដោះស្រាយវិវាទពាណិជ្ជកម្មនៅកម្ពុជា។ លើសពីនេះទៀត ធនធានមនុស្ស គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ចំពោះគ្រប់វិស័យដើម្បីអភិវឌ្ឍន៍ប្រទេសជាតិឱ្យមានការរីកចម្រើន។ ជាពិសេស **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** គឺជាគ្រឹះស្ថានសិក្សាសាធារណៈ ដែលបណ្តុះបណ្តាលនិស្សិត ផ្តល់ចំណេះដឹងច្រើនមុខវិជ្ជា និងមុខជំនាញ ជាពិសេស គឺជំនាញសេដ្ឋកិច្ច និងច្បាប់។ ដូច្នេះនាងខ្ញុំសង្ឃឹមថាស្នាដៃនេះនឹងផ្តល់ចំណេះដឹងថ្មី គុណភាព គុណធម៌ ប្រសិទ្ធភាព ដែលជាតម្រូវការចំបាច់សម្រាប់ប្រើប្រាស់ក្នុងវិស័យការងារនាពេលអនាគត។

ជាការពិតណាស់រាល់កម្រងស្នាដៃនីមួយៗ រមែងជៀសមិនផុតពីការមានកំហុសឆ្គង ឬចំនុចខ្វះខាតណាមួយជាក់ជាពុំខាន។ អាស្រ័យហេតុនេះ នាងខ្ញុំរីករាយស្វាគមន៍នឹងទទួលយក រាល់មតិរិះគន់ និងកែប្រែចំណុចខ្វះខាតដែលកើតមានដោយចេតនាក្តី ដោយអចេតនាក្តីពីសំណាក់លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ លោកលោកស្រី និងមិត្តអ្នកអានដែលមានបំណងរិះគន់ដើម្បីស្ថាបនាឱ្យសារណាមួយនេះកាន់តែល្អប្រសើរជាងមុន។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម**……………………………………………………………………....................................១

**ជំពូកទី១**

**សញ្ញាណនៃមជ្ឈត្តការពាណិជ្ជកម្ម**

**១.១ និយមន័យ និងចរិតលក្ខណៈនៃមជ្ឈការពាណិជ្ជកម្ម** ...............................................៤

**១.២ ប្រវត្តិនៃមជ្ឈត្តការពាណិជ្ជកម្ម** ..................................................................................៦

**១.៣ ប្រភេទផ្សេងៗនៃមជ្ឈត្តការពាណិជ្ជកម្ម** ....................................................................៧

**១.៤ មជ្ឈមណ្ឌលមជ្ឈត្តការពាណិជ្ជកម្មនៅកម្ពុជា**...........................................................៨

**១.៥ ដែនយុត្តាធិការនៃវេទិការមជ្ឈត្តការពាណិជ្ជកម្ម**...............................................៩

១.៥.១ វិវាទពាណិជ្ជកម្ម.................................................................................................... ១០

១.៥.២ កិច្ចព្រមព្រៀងផ្សះផ្សា ...........................................................................................១៣

១.៥.៣ មូលដ្ឋានក្នុងកិច្ចសន្យា............................................................................................១៣

**១.៦ គុណសម្បត្តិនិងគុណវិបត្តិនៃមជ្ឈត្តការ** ........................................................................១៧

១.៦.១ គុណសម្បត្តិនៃមជ្ឈត្តការ .......................................................................................១៧

១.៦.២  គុណវិបត្តិនៃមជ្ឈត្តការ........................................................................................... ១៩

**ជំពូកទី២**

**ដំណើរការនៃនីតិវិធីមជ្ឈត្តការពាណិជ្ជកម្ម**

**២.១ ការផ្តួចផ្តើមដំណើរការមជ្ឈត្តការ** ...................................................................................២៣

២.១.១ ការដាក់ពាក្យរបស់ភាគីបណ្តឹង.................................................................................២៤

២.១.២ ការដាក់ពាក្យរបស់ភាគីឆ្លើយតប ..............................................................................២៥

**២.២ ការជ្រើសរើស និងការជំទាស់នឹងវេទិការមជ្ឈត្តកម្ម**.....................................................២៦

២.២.១ ការជ្រើសរើសមជ្ឈត្តករ.............................................................................................២៦

២.២.២ ការជំទាស់នឹងមជ្ឈត្តករដែលត្រូវបានជ្រើសរើស ......................................................២៦

២.២.៣ ការជំទាស់នឹងយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្ម .............................................. ២៧

**២.៣. ដំណើរការមុនសវនាការ**.......................................................................................២៨

២.៣.១ វិធានគ្រប់គ្រងនីតិវិធី.................................................................................................២៨

២.៣.២ ទីកន្លែងមជ្ឈត្តការ.....................................................................................................២៨

២.៣.៣ ភាសា........................................................................................................................២៨

២.៣.៤ សន្ធានកម្ម .................................................................................................................២៩

២.៣.៥ វិធានការបណ្តោះអាសន្ន ..........................................................................................៣០

២.៣.៦ ការបង្ហាញព័ត៌មានឱ្យដឹង ឬការជូនដំណឹងគ្នាទៅវិញទៅមក................................៣០

២.៣.៧ អ្នកជំនាញ..................................................................................................................៣១

**២.៤. សវនាការមជ្ឈត្តការ** ...................................................................................................៣១

**២.៥. ការធ្វើសេចក្តីសម្រេច** ..................................................................................................៣២

**២.៦. ការប្តឹងឧបាស្រ័យនឹងការដាក់ឱ្យអនុវត្ត** .......................................................................៣៤

២.៦.១ ការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ ..................................................................................៣៤

២.៦.២ ការទទួលស្គាល់និងការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ.......................................................៣៥

២.៦.៣ ការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យអន្តរជាតិ .......................................................................៣៧

**សេចក្តីសន្និដ្ឋាន** ……………………………………………………………….............................៣៩

**អនុសាសន៍** ..........................................................................................................................៤០

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

នាប៉ុន្មានទសវត្សចុងក្រោយនេះ យើងសង្កេតឃើញថាសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ជាមូលហេតុទាក់ទាញអ្នកវិនិយោគទាំងក្នុង និងក្រៅប្រទេសមកវិនិយោគនៅកម្ពុជា ដែលបណ្តាលឱ្យមានសកម្មភាពពាណិជ្ជកម្មកើតមានឡើងជាហូរហែរ។ ទន្ទឹមនឹងកំណើននៃសកម្មភាពពាណិជ្ជកម្ម ការកើតមានវិវាទពាណិជ្ជកម្មក៏រមែងជារឿងដែលជៀសមិនផុត។ ជាទូទៅ ពាណិជ្ជកររមែងចង់រកវេទិការដ៏សមស្របណាមួយដើម្បីដោះស្រាយវិវាទច្រើនជាជាងការទៅដោះស្រាយនៅតុលាការ។

"ការដោះស្រាយវិវាទពាណិជ្ជកម្មឱ្យបានរហ័ស ងាយស្រួល និងប្រកបដោយប្រសិទ្ធភាពខ្ពស់ មានសារៈសំខាន់សម្រាប់ធ្វើឱ្យអាជីវករមានទំនុកចិត្តក្នុងការពង្រីកប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។ ប៉ុន្តែការដោះស្រាយវិវាទពាណិជ្ជកម្មនៅកម្ពុជាហាក់នៅមានលក្ខណៈពិបាក ហើយប្រព័ន្ធដោះស្រាយវិវាទទាំងផ្លូវការ និងមិនផ្លូវការមិនទាន់ដំណើរការសមស្របនៅឡើយ។"[1] អាស្រ័យហេតុនេះ អាជីវករភាគច្រើនតែងគិតថា ការដោះស្រាយវិវាទនៅតុលាការ ពុំមែនជាវិធីល្អសម្រាប់ដោះស្រាយវិវាទទេ។[2] ដូច្នេះហើយ អាជីវករភាគច្រើនសុខចិត្តរងការខាតបង់ និងព្យាយាមក្នុងការជៀសវាងឱ្យឆ្ងាយពីវិវាទ ជាជាងការប្រើសិទ្ធិស្របច្បាប់របស់ខ្លួនដើម្បីទាមទារអ្វីដែលខ្លួនគួរតែទទួលបានតាមផ្លូវច្បាប់។

វិធានការមួយដែលរាជរដ្ឋាភិបាលកម្ពុជាបានជ្រើសរើសយកមក ដើម្បីកែលម្អប្រព័ន្ធដោះស្រាយវិវាទពាណិជ្ជកម្មនៅកម្ពុជា គឺការបង្កើតមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ បច្ចុប្បន្ននេះ យើងសង្កេតឃើញថា មានកំណើននៃវិវាទដែលត្រូវបានដោះស្រាយដោយមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មដែលគួរតែរាប់បញ្ចូលថាជាការបោះជំហានដ៏វិជ្ជមានមួយរបស់កម្ពុជា។ តាមការដកស្រង់យកបទពិសោធន៍ពីប្រទេសជាច្រើន ជាពិសេសប្រទេសដែលមានប្រព័ន្ធតុលាការដែលមានដំណើរការល្អ ឃើញថាការបង្កើតយន្តការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ អាចជួយកែលម្អបរិយាកាសអាជីវកម្ម ដោយធ្វើឱ្យអាជីវករ អាចដោះស្រាយវិវាទបានយ៉ាងងាយស្រួល និងមានប្រសិទ្ធភាព។[3] ប៉ុន្តែយន្តការនេះចាំបាច់តម្រូវឱ្យមជ្ឈមណ្ឌលដែលដោះស្រាយវិវាទពាណិជ្ជកម្មត្រូវតែមានភាពយុត្តិធម៌ ឯករាជ្យ និងមានថ្លៃសេវាទាបដើម្បីដោះស្រាយវិវាទ។ កត្តាទាំងនេះនឹងជំរុញឱ្យមានកំណើនតម្រូវការសេវាមជ្ឈត្តការនឹងធ្វើឱ្យអាជីវករក៏ដូចជាវិនិយោគិនកាន់តែមានទំនុកចិត្តមកលើ

[1] ព្រឹត្តិបត្រស្តីពីបញ្ហាអាជីវកម្ម ការដោះស្រាយវិវាទពាណិជ្ជកម្មនៅកម្ពុជា និងផែនការបង្កើតមជ្ឈមណ្ឌលនៃមជ្ឈត្តការ (ភ្នំពេញ៖អង្គការអភិវឌ្ឍន៍ ឯកជនតំបន់ទន្លេមេគង្គ ឆ្នាំ២០០៧)។

[2] ដូចខាងលើ។

[3] ដូចខាងលើ។

មជ្ឈមណ្ឌលនេះ។ ជាក់ស្តែងដើម្បីសិក្សាឱ្យកាន់តែច្បាស់ គួរតែលើកយកកំណែទម្រង់មួយក្នុងចំណោមកំណែទម្រង់ដ៏ជោគជ័យជាច្រើនរបស់កម្ពុជាមកធ្វើការប្រៀបធៀបនោះគឺក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលជមជ្ឈមណ្ឌលមជ្ឈត្តការសម្រាប់ដោះស្រាយវិវាទការងារ យ៉ាងមានប្រសិទ្ធភាពចាប់តាំងពីត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៣។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ជាគំរូបង្ហាញថាគេអាចបង្កើតស្ថាប័នដោះស្រាយវិវាទប្រកបដោយតម្លាភាព ដែលជាកត្តានាំឱ្យសមាគមអាជីវកម្មមានបំណងប្រើប្រាស់មជ្ឈត្តការដើម្បីដោះស្រាយវិវាទពាណិជ្ជកម្មដូចគ្នា។[4]

ជាលទ្ធផល រដ្ឋសភាកម្ពុជាបានអនុម័តច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មកាលពីខែមីនា ឆ្នាំ ២០០៦។ តាមរយៈច្បាប់នេះ រាជរដ្ឋាភិបាលបានបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដើម្បីគ្រប់គ្រងដំណើរការមជ្ឈត្តការនៅកម្ពុជា។ ហើយបច្ចុប្បន្នមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មកម្ពុជាបានដំណើរការល្អ ហើយអ្នកអនុវត្តក៏បានយល់ដឹងពីគោលគំនិត និងការអនុវត្តនៃការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការនេះបានច្បាស់លាស់ហើយ។ ប៉ុន្តែទោះបីជាច្បាប់ស្តីពីមជ្ឈត្តការពាណិជ្ជកម្មនៅកម្ពុជាមានសុពលភាពអនុវត្តជាង១៤ឆ្នាំហើយក៏ដោយ ក៏នៅតែមានពាណិជ្ជករ និងវិនិយោគិនមួយចំនួនដែលមិនទាន់ស្គាល់ពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មច្បាស់ ពោលបុគ្គលទូទៅតែងច្រឡំវេទិការមជ្ឈត្តកម្មពាណិជ្ជកម្ម នឹងក្រុមប្រឹក្សាអាជ្ញាកណ្តាលដោះស្រាយវិវាទការងារ។[5] ប៉ុន្តែគួរបញ្ជាក់ដែរថា វេទិការទាំងពីរនេះមានតួនាទី ខុសគ្នាត្រង់ វេទិការមជ្ឈត្តកម្មការងារដោះស្រាយបានតែវិវាទការងារ ចំណែកឯវេទិការមជ្ឈត្តកម្មពាណិជ្ជកម្មអាចសម្រេចបានតែចំណុចវិវាទដែលជារឿងពាណិជ្ជកម្មដោយមិនរាប់បញ្ចូលរឿងដទៃទៀតក្រៅពីពាណិជ្ជកម្មឡើយ។

ដូច្នេះដើម្បីជំនួយដល់ការយល់ដឹងពីមជ្ឈត្តការពាណិជ្ជកម្មឱ្យកាន់តែច្បាស់ ប្រធានបទនៃសារណាមួយនេះផ្តោតសំខាន់លើសញ្ញាណនៃមជ្ឈត្តការពាណិជ្ជកម្មនៅកម្ពុជា ដំណើរការនៃមជ្ឈត្តការពាណិជ្ជកម្ម និងការប្រៀបធៀបគុណសម្បត្តិ និងចំនុចខ្វះខាតនៃមជ្ឈត្តការពាណិជ្ជកម្មនៅកម្ពុជា។ ទាក់ទិននឹងប្រធានបទនេះដែរ មានសំណួរគត្តិយុត្តិមួយចំនួនបានលេចឡើងជាអាទិ៍ដូចជា តើអ្វីទៅជាមជ្ឈត្តការពាណិជ្ជកម្ម? តើការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការត្រូវគោរពតាមនីតិវិធីដូចម្តេចខ្លះ? តើការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការផ្តល់ផលប្រយោជន៍អ្វីខ្លះ?

---

[4] ដូចខាងលើ។

[5] អត្ថបទស្តីពី ចំណុចវិវាទដែលអាចសម្រេចបានដោយវេទិកាមជ្ឈត្តកម្មពាណិជ្ជកម្មនៅកម្ពុជា រៀបរៀងដោយ លោកមេធាវី គឹម សាន។

ដើម្បីឆ្លើយតបនឹងសំណួរគត្តិយុត្តដែលបានចោទឡើងខាងលើនេះ ក៏ដូចជាសំណួរផ្សេងទៀតដែលអាចកើតមានចំពោះប្រធានបទទាំងមូល នាងខ្ញុំនឹងធ្វើការបែងចែកប្រធានបទនេះជាពីរជំពូកគឺ **សញ្ញាណនៃមជ្ឈត្តការពាណិជ្ជកម្មនៅកម្ពុជា(ជំពូកទី១) និងដំណើរការនៃមជ្ឈត្តការពាណិជ្ជកម្មនៅកម្ពុជា(ជំពូកទី២)**។

# ជំពូកទី១
# សញ្ញាណនៃមជ្ឈត្តការ
# ពាណិជ្ជកម្ម

# ជំពូកទី១

# សញ្ញាណនៃមជ្ឈត្តការពាណិជ្ជកម្ម

## ១.១ និយមន័យ និងចរិតលក្ខណៈនៃមជ្ឈការពាណិជ្ជកម្ម

តាមខ្លឹមសារនៃមាត្រា២ នៃច្បាប់ស្តីពីមជ្ឈការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់និយមន័យនៃពាក្យ "មជ្ឈត្តការ" ថាជាការផ្សះផ្សាវិវាទដោយប្រើប្រាស់វេទិការមជ្ឈកម្មហើយអាចស្ថិតក្នុង ឬក្រៅក្របខ័ណ្ឌនៃការគ្រប់គ្រងរបស់ស្ថាប័នផ្សះផ្សារអចិន្ត្រៃយ៍។[6] មជ្ឈត្តការ គឺជាវិធីសាស្ត្រដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ភាគីដាក់វិវាទរបស់ខ្លួនជូនភាគីទីបីដែលអព្យាក្រឹត្យមួយ (ដែលជាទូទៅហៅថា "មជ្ឈត្តករ" ឬ បើច្រើនជាងម្នាក់ ហៅថា"ក្រុមមជ្ឈត្តករ" ឬ"វេទិការមជ្ឈត្តកម្ម") ហើយពួកគាត់ធ្វើការពិចារណាពីភស្តុតាងដែលភាគីបានដាក់ជូន និង ចេញសេចក្តីសម្រេចមួយ ហៅថា"មជ្ឈត្តវិនិច្ឆ័យ"។[7] ជាទូទៅមជ្ឈត្តវិនិច្ឆ័យតែងតែភ្ជាប់កាតព្វកិច្ចចំពោះគូភាគីទាំងអស់ ប៉ុន្តែក្នុងករណីខ្លះ មជ្ឈត្តវិនិច្ឆ័យក៏អាចមិនភ្ជាប់កាតព្វកិច្ចចំពោះគូភាគីដែរ។[8] ចំពោះមជ្ឈត្តវិនិច្ឆ័យដែលភ្ជាប់កាតព្វកិច្ចចំពោះគូភាគី នឹងមានអានុភាពអនុវត្តនៅតុលាការថ្នាក់ជាតិ។

នៅពេលគូភាគីជ្រើសយកមជ្ឈត្តការពាណិជ្ជកម្មមកដោះស្រាយវិវាទ គូភាគីទទួលបានស្វ័យភាពលើការគ្រប់គ្រងនីតិវិធីនៃមជ្ឈត្តការនោះ។ កត្តានេះមានសារៈសំខាន់ណាស់ចំពោះគូភាគី ជាពិសេសគូភាគីបរទេសដោយសារតែករណីមជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិ គូភាគីអាចនឹងមានការភ័យខ្លាចថាតុលាការរដ្ឋម្ចាស់ផ្ទះនឹងមានភាពលំអៀង។ មិនតែប៉ុណ្ណោះ ដោយផ្អែកលើគោលការណ៍សេរីភាពខាងឆន្ទៈ គូភាគីអាចជ្រើសរើសចំនួនមជ្ឈត្តករ វិធានច្បាប់សម្រាប់គ្រប់គ្រង និងភាពបត់បែននៃនីតិវិធីតាមតម្រូវការរបស់ខ្លួនដែលជាហេតុធ្វើឱ្យមជ្ឈការពាណិជ្ជកម្មនាពេលបច្ចុប្បន្នកំពុងក្លាយជាជម្រើសក៏ពេញនិយមរបស់គូភាគីក្នុងការដោះស្រាយវិវាទពាណិជ្ជកម្ម។ ចរិតលក្ខណៈនៃមជ្ឈការពាណិជ្ជកម្មរួមមាន[9]៖

- **ឆន្ទៈរបស់គូភាគី**

ឆន្ទៈរបស់គូភាគីផ្តល់អំណាចដល់មជ្ឈត្តករក្នុងការសម្រេចសេចក្តីលើវិវាទរបស់ពួកគេ។ មិនតែប៉ុណ្ណោះ ឆន្ទៈរបស់គូភាគីក៏អាចកំណត់ទំហំអំណាចរបស់មជ្ឈត្តករផងដែរ ដោយហេតុថា មជ្ឈត្តករអាចដោះស្រាយបាន

---

[6] ច្បាប់ស្តីពីមជ្ឈការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ មាត្រា២។

[7] ស្ទីវិន អ៊ែម អូស្ទើតមីឡឺរ៍ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ប្រទេសកម្ពុជា (ភ្នំពេញ ឆ្នាំ២០១០) ១៥៤។

[8] ដូចខាងលើ។

[9] ម៉ាហ្កាវ៉េត ម៉ូសេស មជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិ (ញ៉ូយក ឆ្នាំ២០០៨) ២-៣។

ត្រឹមតែទំហំវិវាទដែលមានចែងក្នុងខចែងស្តីពីមជ្ឈត្តការតែប៉ុណ្ណោះ។ មជ្ឈត្តករត្រូវគោរពតាមវិធាន នីតិវិធី និងច្បាប់ដែលភាគីបានព្រមព្រៀងគ្នា។ ជាទូទៅ គូភាគីបង្ហាញឆន្ទៈរបស់ខ្លួនក្នុងការជ្រើសយកមជ្ឈត្តការជាវិធីដោះស្រាយវិវាទដែលអាចនឹងកើតមានឡើងតាមរយៈការបញ្ចូលខចែងស្តីពីមជ្ឈត្តការទៅក្នុងកិច្ចសន្យាគោល។ ប៉ុន្តែបើគូភាគីខកខានក្នុងការបញ្ចូលនូវខចែងស្តីពីមជ្ឈត្តការទៅក្នុងកិច្ចសន្យាគោល គូភាគីក៏នៅតែអាចជ្រើសយកមជ្ឈត្តការក្នុងដោះស្រាយវិវាទ ទោះបីជាវិវាទនោះបានកើតឡើងហើយក៏ដោយតាមរយៈកិច្ចព្រមព្រៀងដោយឡែក។

- **ការសម្រេចសេចក្តីដោយបុគ្គលដែលមិនមែនជាសមាជិករាជការ**

ដោយសារតែមជ្ឈត្តករជាប្រជាជនសាមញ្ញហើយពួកគាត់ពុំមែនជាសាមជិករាជការ ការសម្រេចចិត្តរបស់ពួកគាត់ផ្តោតសំខាន់លើផលប្រយោជន៍របស់គូភាគី។ បើប្រៀបធៀបជាមួយចៅក្រមដែលជាសមាជិករាជការ ពួកគាត់ត្រូវគិតគូរជាសំខាន់លើផលប្រយោជន៍ និងសណ្តាប់ធ្នាប់សាធារណៈ។ ម្យ៉ាងវិញទៀត ដោយសារតែមជ្ឈត្តករត្រូវបានជ្រើសរើសដោយគូភាគី ពួកគាត់ត្រូវមានការយកចិត្តទុកដាក់ខ្ពស់ ការគិតគូរល្អិតល្អន់ និងមានហេតុផលសមស្របទើបពួកគាត់អាចនឹងត្រូវជ្រើសរើសនាពេលក្រោយៗទៀត។ មជ្ឈត្តករពុំចាំបាច់ជាមេធាវីទេ ពួកគេអាចជាបុគ្គលដែលមានជំនាញដូចជា វិស្វករជាដើម។ ជាទូទៅ ការដោះស្រាយវិវាទតែងតែមានមជ្ឈត្តករបីនាក់។ ភាគីម្ខាងៗត្រូវជ្រើសរើសមជ្ឈត្តករម្នាក់ ហើយមជ្ឈត្តករទាំងពីរនាក់នោះត្រូវជ្រើសរើសមជ្ឈត្តករទីបី។ គូភាគីអាចប្តឹងជំទាស់នឹងមជ្ឈត្តករបាននៅមជ្ឈមណ្ឌលមជ្ឈត្តការ ឬតុលាការនៅពេលរកឃើញមូលហេតុដែលអាចនាំឱ្យមានភាពលំអៀង ឬប៉ះពាល់ដល់ឯករាជ្យភាព។

- **សេចក្តីសម្រេចចុងក្រោយនឹងមានអានុភាពចាប់បង្ខំ**

មូលហេតុចម្បងដែលគូភាគីជ្រើសយកមជ្ឈត្តការមកដោះស្រាយវិវាទ ព្រោះមជ្ឈត្តវិនិច្ឆ័យដែលសម្រេចដោយវេទិការមជ្ឈត្តកម្មជាសេចក្តីសម្រេចចុងក្រោយ និងមានអានុភាពចាប់បង្ខំហើយជាទូទៅពុំអាចត្រូវបានប្តឹងទាស់នៅតុលាការថ្នាក់លើទេ។ ប៉ុន្តែមានករណីមួយចំនួនដែលអាចប្តឹងទាស់បានដូចជា វិការៈក្នុងដំណើរនីតិវិធី ឬមជ្ឈត្តករបានសម្រេចសេចក្តីលើសពីដែនយុត្តាធិការរបស់ខ្លួន។ ភាគីដែលឈ្នះអាចយកមជ្ឈត្តវិនិច្ឆ័យទៅអនុវត្តន៍នៅទីកន្លែងដែលមជ្ឈត្តការប្រព្រឹត្តឡើង ឬទីកន្លែងដែលភាគីដែលចាញ់មានទ្រព្យសម្បត្តិតាំងនៅ។ ភាគីដែលចាញ់អាចយល់ព្រមតាមមជ្ឈត្តវិនិច្ឆ័យដោយស្ម័គ្រចិត្ត ប៉ុន្តែករណីដែលភាគីដែលចាញ់មិនព្រម អាចប្តឹងទាស់ក្នុងលក្ខណ្ឌរឹតត្បឹត ដែលត្រូវតែឈរលើមូលដ្ឋានកំហុសនីតិវិធី ហើយកំហុសសារធាតុមិនថាជាកំហុសអង្គហេតុ ឬអង្គច្បាប់ពុំអាចជាមូលហេតុនៃការប្តឹងទាស់ឡើយ ពោលមជ្ឈត្តវិនិច្ឆ័យនៅតែអាចអនុវត្តបានជា

ធម្មតា។ នៅពេលដែលមជ្ឈត្តវិនិច្ឆ័យត្រូវបានទទួលស្គាល់ដោយយុត្តាធិការនៃកន្លែងដែលភាគីស្នើសុំអនុវត្ត នោះ មជ្ឈត្តវិនិច្ឆ័យនឹងមានអានុភាពអនុវត្តដូចជាសាលក្រមដែរ។

## ១.២ ប្រវត្តិនៃមជ្ឈត្តការពាណិជ្ជកម្ម

មជ្ឈត្តការមានប្រវត្តិជាយូរលង់ណាស់មកហើយតាំងពីក្រិចសម័យបុរាណ និងត្រូវបានកត់ត្រាក្នុងព្រះគម្ពីរប៊ីប្លរបស់សាសនាគ្រីស្ត។[10] មជ្ឈត្តការពាណិជ្ជកម្មទំនើបត្រូវបានបង្កើតឡើងជាលើកដំបូងនៅទ្វីបអឺរ៉ុបក្នុងយុគមជ្ឈឹមសម័យ។[11] ជាញឹកញាប់ពាណិជ្ជករត្រូវធ្វើដំណើរយ៉ាងឆ្ងាយដើម្បីធ្វើជំនួញហើយចំណាយធ្វើដំណើរក៏ថ្លៃ ហើយតែងជួបប្រទះគ្រោះថ្នាក់ជាច្រើន។ ដូច្នេះវិវាទនានាត្រូវដោះស្រាយឱ្យបានឆាប់រហ័ស និងជិតទីកន្លែងធ្វើជំនួញនោះ។ ពេលនោះតុលាការមិនអាចដោះស្រាយវិវាទឆាប់រហ័សទេហើយក៏គ្មានចំណេះដឹងពីបទដ្ឋានពាណិជ្ជកម្មរបស់អាជីវករដែលត្រូវបានបង្កើតឡើងដើម្បីសម្រួលទំនាក់ទំនងពាណិជ្ជកម្មដល់ភាគីដែលមកពីប្រទេសខុសគ្នា និងមានវប្បធម៌ផ្សេងគ្នា។ ដោយសមត្ថកិច្ចរបស់តុលាការនៅមានកម្រិត ពាណិជ្ជករបានបង្កើតវេទិការធ្វើមជ្ឈត្តការជាឯកជន ដើម្បីដោះស្រាយវិវាទយ៉ាងមានប្រសិទ្ធភាពដោយប្រើប្រាស់អ្នកជំនាញពាណិជ្ជកម្ម និងបទដ្ឋានពាណិជ្ជកម្ម។ នៅកំឡុងសតវត្សរ៍ទី១៧ និងទី១៨ ពេលដែលនិគមជនអង់គ្លេសផ្លាស់ទីលំនៅទៅទ្វីបអាមេរិក ពួកគេបាននាំមកនូវបែបផែនមជ្ឈត្តការទាំងនេះ។ ជាលទ្ធផល មជ្ឈត្តការបានដើរតួនាទីសំខាន់ក្នុងការដោះស្រាយវិវាទពាណិជ្ជកម្មក្នុងទឹកដីអាណានិគមអង់គ្លេសក្នុងទ្វីបអាមេរិក។ នៅឆ្នាំ១៧៦៨ ស្ថាប័នមជ្ឈត្តការអចិន្ត្រៃយ៍ដំបូងបង្អស់ ត្រូវបានបង្កើតឡើងដោយសភាពាណិជ្ជកម្មញូវយ៉ក។ ប៉ុន្តែពេលនោះតុលាការនៅសហរដ្ឋអាមេរិក និងបណ្តាប្រទេសមួយចំនួនទៀត មិនអាចអនុវត្តន៍ មជ្ឈត្តវិនិច្ឆ័យបានឡើយទើបគេចាត់ទុកជាផ្លូវការ ថាមជ្ឈត្តការស្ថិតនៅក្រៅប្រព័ន្ធតុលាការ។

នៅសតវត្សរ៍ទី២០ ដោយសារកំណើនសំណុំរឿងក្តី តុលាការនៃប្រទេសជាច្រើនបានចាប់ផ្តើមចាត់ទុកមជ្ឈត្តការជាវិធីសាស្ត្រស្របច្បាប់មួយក្នុងការដោះស្រាយវិវាទ។ នៅសហរដ្ឋអាមេរិក ច្បាប់ស្តីពីមជ្ឈត្តការរដ្ឋសហព័ន្ធឆ្នាំ១៩២៥ បានផ្តល់សុពលភាពដល់ខចែងស្តីពីមជ្ឈត្តការនៅក្នុងកិច្ចសន្យាពាណិជ្ជកម្មឱ្យមានសុពលភាពអនុវត្ត។ ប្រទេសផ្សេងៗបានអនុវត្តន៍តាមយ៉ាងឆាប់រហ័ស ដែលនាំឱ្យវេទិការមជ្ឈត្តកម្មមានការរីកចម្រើនយ៉ាងឆាប់រហ័សនៅពាសពេញពិភពលោក។ នៅឆ្នាំ១៩២៣ សភាពាណិជ្ជកម្មអន្តរជាតិទីក្រុងប៉ារីស បានបង្កើត

---

[10] ស្ទីវិន បែនណែត មជ្ឈត្តការទស្សនាទានសំខាន់ៗ (ឆ្នាំ២០០២)។

[11] សារ៉ា រ៉ូដល ខូល និង គ្រីស្ទីន អ៊ែម ប្លែងឃ្លី មជ្ឈត្តការ សៀវភៅណែនាំពីការដោះស្រាយវិវាទ (ឆ្នាំ២០០៥) ៣១៨-៣២០។

តុលាការមជ្ឈត្តការអន្តរជាតិ ដែលល្បីល្បាញបំផុតមួយនៅក្នុងពិភពលោក។ វេទិការមជ្ឈត្តកម្មសំខាន់ផ្សេងៗទៀតរួមមាន សមាគមមជ្ឈត្តការអាមេរិកទីក្រុងញូវយ៉ក និងតុលាការមជ្ឈត្តការអន្តរជាតិទីក្រុងឡុងដ៍។

នាប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ កំណើនសេដ្ឋកិច្ចនៅអាស៊ីបាននាំឱ្យមានការកើនឡើង វេទិការមជ្ឈត្តកម្មគួរឱ្យកត់សម្គាល់។ បច្ចុប្បន្ននេះ វេទិការដ៏ធំបំផុតចំនួនបីនៅអាស៊ី គឺគណៈកម្មការមជ្ឈត្តការផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្មអន្តរជាតិប្រទេសចិន មជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិទីក្រុងហុងកុង និងមជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិសិង្ហបុរី ហើយក៏មានវេទិការមជ្ឈត្តការផ្សេងៗទៀត មាននៅប្រទេសជប៉ុន ថៃ វៀតណាម ម៉ាឡេស៊ី តៃវ៉ាន់ ឥណ្ឌា ឥណ្ឌូនេស៊ី និងប្រទេសកម្ពុជា។

## ១.៣ ប្រភេទផ្សេងៗនៃមជ្ឈត្តការពាណិជ្ជកម្ម

ជាទូទៅមជ្ឈត្តការជាវិធីដោះស្រាយវិវាទមួយដែលចងភ្ជាប់កាតព្វកិច្ច។[12] ភាគីវិវាទត្រូវបង្ហាញភស្តុតាងរបស់ខ្លួនហើយមជ្ឈត្តករជាអ្នកចេញសេចក្តីសម្រេចមួយដែលចងភ្ជាប់កាតព្វកិច្ចដែលភាគីត្រូវតែគោរពតាម។ ភាគីមានសិទ្ធិតិចតួចបំផុតក្នុងការប្តឹងឧបាស្រ័យហើយសេចក្តីសម្រេចនោះអាចដាក់ឱ្យអនុវត្តដោយតុលាការដែលទម្រង់មជ្ឈត្តកាបុរាណនេះ ហៅថា"មជ្ឈត្តការភ្ជាប់កាតព្វកិច្ច"។[13] ប៉ុន្តែមជ្ឈត្តការមិនភ្ជាប់កាតព្វកិច្ចក៏កំពុងក្លាយជាជម្រើសដ៏ពេញនិយមដែរ។ មជ្ឈត្តការមិនភ្ជាប់កាតព្វកិច្ចខុសពីមជ្ឈត្តការចងភ្ជាប់កាតព្វកិច្ចត្រង់ថាភាគីនីមួយៗអាចបដិសេធនឹងមជ្ឈត្តវិនិច្ឆ័យក្នុងរយៈពេលខ្លីមួយក្រោយពេលចេញសេចក្តីសម្រេច។ មជ្ឈត្តការមិនភ្ជាប់កាតព្វកិច្ចត្រូវបានប្រើប្រាស់ដើម្បីជួយរក្សាទំនាក់ទំនងរបស់ភាគីវិវាទ។ មជ្ឈត្តករអាចចេញមជ្ឈត្តវិនិច្ឆ័យក្នុងការដោះស្រាយវិវាទ។ គូភាគីអាចទទួលយកមជ្ឈត្តវិនិច្ឆ័យនេះដើម្បីចរចា និងបញ្ចប់វិវាទរបស់ខ្លួន ឬក្នុងករណីដែលមជ្ឈត្តវិនិច្ឆ័យនោះឆ្លើយតបនឹងផលប្រយោជន៍របស់ខ្លួន។ ប៉ុន្តែគុណវិបត្តិគឺ ខាតពេលវេលា និងធនធាន បើភាគីបដិសេធនឹងសេចក្តីសម្រេចហើយប្តឹងទៅតុលាការ ឬកន្លែងផ្សេងទៀត។ មជ្ឈត្តការមិនភ្ជាប់កាតព្វកិច្ចស្រដៀងគ្នានឹងសន្ធានកម្មព្រោះមានការចរចារគ្នា ហើយតាមរយៈនេះ គូភាគីជាអ្នកគ្រប់គ្រងដំណើរការ និងលទ្ធផលនៃការចរចាទាំងស្រុង។[14] ផ្ទុយទៅវិញ មជ្ឈត្តការភ្ជាប់កាតព្វកិច្ចដូចគ្នាទៅនឹងដំណើរការបណ្តឹងទៅតុលាការដោយសារតែនីតិវិធីមានការពាក់ព័ន្ធនឹងសេចក្តីសម្រេចចុងក្រោយ ដែលត្រូវធ្វើឡើងដោយភាគីអព្យាក្រឹតមួយ។

[12] ច្បាប់ស្តីពីមជ្ឈការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ មាត្រា៤៥។

[13] ស្ទីវិន អ៊ែម អូស្ទើតមីឡឺរ៍ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា (ភ្នំពេញ ឆ្នាំ២០១០) ១៥៤។

[14] ដូចខាងលើ។

មជ្ឈត្តការក៏អាចត្រូវបានបែងចែកជាប្រភេទមជ្ឈត្តការដែលមានការគ្រប់គ្រង ឬមជ្ឈត្តការពិសេស។[15] មជ្ឈត្តការមានការគ្រប់គ្រង សំដៅលើមជ្ឈត្តការដែលធ្វើឡើងនៅមជ្ឈមណ្ឌលមជ្ឈត្តការដូចជា មជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិសិង្ហបុរី ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការកម្ពុជា។ មជ្ឈមណ្ឌលមជ្ឈត្តការទាំងនេះមានផ្តល់បន្ទប់មួយសម្រាប់ធ្វើសវនាការ បញ្ជីរាយនាម មជ្ឈត្តករ ការចែងវិធាននីតិវិធីសម្រាប់ដំណើរការ និងសេវាកម្មដទៃផ្សេងទៀត ដែលជាទូទៅត្រូវមានការបង់ថ្លៃ។ មជ្ឈត្តការពិសេសសំដៅដល់ជម្រើសរបស់គូភាគីក្នុងការបង្កើតវេទិកាផ្ទាល់ខ្លួនក្នុងគោលបំណងជាក់លាក់ណាមួយក្នុងការដោះស្រាយវិវាទ។ គុណសម្បត្តិរបស់មជ្ឈត្តការមានការគ្រប់គ្រង គឺភាពលម្អិតនៃដំណើរការត្រូវបានកំណត់ជាស្រេច។ ភាគីគ្រាន់តែត្រូវគោរពតាមនីតិវិធីរបស់វេទិការមជ្ឈត្តកម្មដែលខ្លួនជ្រើសរើសតែប៉ុណ្ណោះ ដើម្បីចាប់ផ្តើមដំណើរការមជ្ឈត្តការ។ ដូច្នេះទើបភាគីភាគច្រើនជ្រើសរើសយកមជ្ឈត្តការមានការគ្រប់គ្រង។ ចំពោះមជ្ឈត្តការពិសេស គូភាគី ឬមេធាវីរបស់គូភាគីត្រូវសម្រេចចិត្តក្នុងការតាក់តែងចំណុចលម្អិតដូចជា វិធាននីតិវិធី ថ្លៃចំណាយមជ្ឈត្តករ ជាដើមនៅពេលចុះកិច្ចសន្យា ឬក្រោយពេលវិវាទបានកើតឡើង។ ប៉ុន្តែមជ្ឈត្តការពិសេសផ្តល់ឱ្យភាគីមានភាពបត់បែនច្រើនលើចំណុចលម្អិតនានារួមទាំងថ្លៃចំណាយ ព្រោះគូភាគីមិនចាំបាច់គោរពតាមវិធានរបស់មជ្ឈមណ្ឌលមជ្ឈត្តការណាមួយឡើយ។

ជារួមមក មជ្ឈត្តការមានការគ្រប់គ្រង ឬមជ្ឈត្តការពិសេស អាចជាមជ្ឈត្តការភ្ជាប់កាតព្វកិច្ច ឬមិនភ្ជាប់កាតព្វកិច្ច។ ប្រភេទនៃមជ្ឈត្តការទាំងនេះត្រូវធ្វើឡើងនៅពេលបង្កើតកិច្ចសន្យា។ បើភាគីចង់ដោះស្រាយវិវាទរបស់ខ្លួនតាមរយៈមជ្ឈត្តការ ពួកគេត្រូវព្រមព្រៀងគ្នាចំពោះទម្រង់មជ្ឈត្តការណាមួយហើយត្រូវបញ្ចូលវាក្នុងខចែងស្តីពីមជ្ឈត្តការនៃកិច្ចសន្យា។

## ១.៤ មជ្ឈមណ្ឌលមជ្ឈត្តការពាណិជ្ជកម្មនៅកម្ពុជា

មជ្ឈមណ្ឌលមជ្ឈត្តការនៅកម្ពុជាមានឈ្មោះថា "មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តកាផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា" ("ម.ជ.ម.")។ មជ្ឈមណ្ឌលនេះត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៦ ដោយច្បាប់ស្តីពីមជ្ឈត្តការពាណិជ្ជកម្ម។[16] អនុលោមតាមច្បាប់ខាងលើ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងអនុក្រឹត្យលេខ ១៨២ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០។ ម.ជ.ម. បានបង្កើតគណៈកម្ម

---

[15] ម៉ាហ្ការ៉េត ម៉ូសេស មជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិ (ញ៉ូយក ឆ្នាំ២០០៨) ៩។

[16] ច្បាប់ស្តីពីមជ្ឈការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ មាត្រា១០។

ការរៀបចំជ្រើសរើសមជ្ឈត្តករដំបូងតាមប្រកាសក្រសួងពាណិជ្ជកម្មលេខ២២៣ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ ២០០៩។

គោលដៅចម្បងរបស់មជ្ឈមណ្ឌលនេះគឺ ផ្តល់ដំណោះស្រាយចំពោះវិវាទពាណិជ្ជកម្មរវាងវិនិយោគិនក្រៅប្រព័ន្ធតុលាការនៅកម្ពុជា។ ម.ជ.ម. បានអនុម័តវិធានមជ្ឈត្តការពាណិជ្ជកម្មរបស់ខ្លួននៅ ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៤។ ចំពោះដំណើរការមជ្ឈត្តការដែលគ្រប់គ្រងដោយ ម.ជ.ម. នឹងត្រូវប្រព្រឹត្តទៅដោយអនុលោមតាមច្បាប់ស្តីពីមជ្ឈត្តការពាណិជ្ជកម្មដែលបានអនុម័តនៅថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៦ និងវិធានមជ្ឈត្តការពាណិជ្ជកម្មរបស់ ម.ជ.ម. ("វិធាន ម.ជ.ម.")។ បច្ចុប្បន្ននេះ វិធានមជ្ឈត្តការរបស់ប្រទេសកម្ពុជាមានភាពស៊ីសង្វាក់គ្នាជាមួយប្រទេសជាង៥០ រួមមានដៃគូពាណិជ្ជកម្មសំខាន់ៗដូចជា ប្រទេសជប៉ុន កូរ៉េខាងត្បូង សិង្ហបុរី ថៃ និងអូស្ត្រាលីជាដើម។ ចំពោះនីតិវិធីលម្អិតនឹងត្រូវរៀបរាប់ក្នុងជំពូកទី២។

យោងតាមមាត្រា១ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ម.ជ.ម. ជាសេវាកម្មឯកជន និងឯករាជ្យ។ នៅពេលដែលភាគីវិវាទជ្រើសយកមជ្ឈមណ្ឌល ម.ជ.ម. គូភាគីត្រូវបង់សេវាដូចជា៖ សេវាចុះបញ្ជី សេវាតែងតាំងមជ្ឈត្តករ ថ្លៃរដ្ឋបាលរបស់មជ្ឈមណ្ឌល កម្រៃសេវាវេទិកាមជ្ឈត្តកម្ម និង កម្រៃសេវាផ្សេងៗ របស់វេទិកាមជ្ឈត្តកម្ម និងម.ជ.ម. (ចំណុច៤១ នៃវិធាន ម.ជ.ម.)។

ឧទាហរណ៍៖ ពេលមានវិវាទ ហើយគូភាគីជ្រើសយកមជ្ឈមណ្ឌល ម.ជ.ម. ហើយគូភាគីសម្រេចយកមជ្ឈត្តករ៣ នាក់ នោះគូភាគីត្រូវចំណាយសេវាតាមតារាងសម្រាប់ភាគីជ្រើសរើស ពោលចំណូលរបស់មជ្ឈត្តករគឺបានមកពីភាគីវិវាទនេះឯង៕

គិតមកទល់ពេលនេះ ម.ជ.ម. បានទទួលសំណុំរឿងវិវាទពាណិជ្ជកម្មចំនួន១៨ករណីហើយក្នុងចំណោមនោះ មាន៧សំណុំរឿងដែលបានបញ្ចប់និងបានចេញមជ្ឈិត្តវិនិច្ឆ័យរួចរាល់។[17]

## ១.៥ ដែនយុត្តាធិការនៃវេទិការមជ្ឈត្តការពាណិជ្ជកម្ម

ការកំណត់ពីដែនយុត្តាធិការនៃវេទិការមជ្ឈត្តការមានសារៈសំខាន់ណាស់។ ការសម្រេចលើចំណុចវិវាទដែលហួសពីដែនយុត្តាធិការនៃវេទិការមជ្ឈត្តកម្មនាំឱ្យមានការប្តឹងជំទាស់នៅដំណាក់កាលអនុវត្ត។ ការកំណត់ពីចំណុចវិវាទដែលអាចសម្រេចដោយវេទិការមជ្ឈត្តកម្មមានទំនាក់ទំនងនឹងច្បាប់នៃប្រទេសដែលមានយុត្តាធិការអនុវត្តសេចក្តីសម្រេច។ ស្ថិតក្នុងលក្ខណ្ឌធម្មតា វិវាទពាណិជ្ជកម្មដែលអាចដោះស្រាយបានតាមច្បាប់កម្ពុជាទាមទារដូចខាងក្រោម៖

[17] https://www.khmertimeskh.com/724106/resolving-commercial-disputes-without-going-to-law- qa/

## ១.៥.១ វិវាទពាណិជ្ជកម្ម

ការកំណត់និយមន័យ "វិវាទពាណិជ្ជកម្ម" ត្រូវអនុលោមតាមខ្លឹមសារដែលមានចែងក្នុងសន្ធិសញ្ញាអន្តរជាតិ ប្រើសម្រាប់អនុវត្តមជ្ឈត្តវិនិច្ឆ័យ ច្បាប់នៃប្រទេសដែលជាទីកន្លែងមជ្ឈត្តការ (ទីកន្លែងដែលដំណើរការមជ្ឈត្តការប្រព្រឹត្តទៅ) និងច្បាប់នៃប្រទេសដែលមានយុត្តាធិការអនុវត្តសេចក្តីសម្រេច។

ដោយសារប្រទេសកម្ពុជាបានក្លាយជាហត្ថលេខី នៃសន្ធិសញ្ញាទីក្រុងញ៉ូវយកស្តីពី ការទទួលស្គាល់ និងការអនុវត្តសេចក្តីសម្រេចមជ្ឈត្តការបរទេសនៅឆ្នាំ១៩៦០ សន្ធិសញ្ញានេះតម្រូវឱ្យបកស្រាយនិយមន័យនៃវិវាទក្នុងន័យទូលាយ ដោយកំណត់ថាវិវាទកើតចេញពីការខ្វែងគំនិតគ្នារវាងបុគ្គលច្រើននាក់ មិនថាមានលក្ខណៈជារូបវន្ត ឬមានលក្ខណៈច្បាប់ឡើយ។[18] ប៉ុន្តែសន្ធិសញ្ញានេះ អនុញ្ញាតឱ្យប្រទេសហត្ថលេខីបកស្រាយពាក្យ "ពាណិជ្ជកម្ម" ក្នុងន័យចង្អៀត និងច្បាស់លាស់ជាមួយប្រទេសណាមួយដែលខ្លួនព្រមព្រៀងជាមួយនៅពេលអនុវត្តសេចក្តីសម្រេចដោយផ្អែកលើគោលការណ៍ឱ្យគ្នាទៅវិញទៅមក។

ចំណែកឯមាត្រា២(ឈ) នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មបានពន្យល់ថាវេទិកាមជ្ឈត្តកម្មអាចសម្រេចបានតែលើវិវាទពាណិជ្ជកម្មតែប៉ុណ្ណោះ ហើយត្រូវឈរលើការបកស្រាយតាមច្បាប់ស្តីពីមជ្ឈការពាណិជ្ជកម្មតែមួយគត់។ និយមន័យនៃពាក្យ "ពាណិជ្ជកម្ម" ត្រូវបានកំណត់ទៅតាមប្រភេទនៃសកម្មភាពជួញដូរនីមួយៗ ។ ដោយសារច្បាប់នេះមិនកំណត់ពីប្រភេទនៃការជួញដូរ មានភាពស្រពិចស្រពិលមួយចំនួនដូចជា៖

- ទំនាក់ទំនងជាមួយបុគ្គល និងស្ថាប័នពាណិជ្ជកម្ម
- ចំនួនទឹកប្រាក់ដែលវេទិកាទទួលដោះស្រាយ
- លក្ខខណ្ឌ ឬលក្ខណៈវិនិច្ឆ័យដទៃទៀត ដែលវេទិកាមួយត្រូវបិទបដិសេធមិនសម្រេចសេចក្តីនៅក្នុងនោះឡើយ។[19]

មាត្រានេះ ទាមទារឱ្យមានការបកស្រាយទូលាយ ដើម្បីគ្រប់ដណ្តប់លើគ្រប់ទំនាក់ទំនងទាំងអស់នៃប្រភេទពាណិជ្ជកម្ម។ ដោយសារតែការកំណត់និយមន័យដ៏ទូលាយនេះ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនឹងគ្របដណ្តប់លើសវនាការមជ្ឈត្តការភាគច្រើននៅក្នុងប្រទេសកម្ពុជានាពេលអនាគត។[20]

---

[18] សន្ធិសញ្ញាទីក្រុងញ៉ូវយក ស្តីពីការទទួលស្គាល់ និងការអនុវត្តសេចក្តីសម្រេចមជ្ឈត្តការបរទេស ឆ្នាំ១៩៥៨ មាត្រា១។

[19] ដូចខាងលើ។

[20] ស្ទីវិន ផៃអែម អូស្ទើតមីឡឺរ៍ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ប្រទេសកម្ពុជា (ភ្នំពេញ ឆ្នាំ២០១០) ១៥៤។

ជាក់ស្តែងច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មបានចែងថា វេទិការមជ្ឈត្តកម្មអាចប្រើ "ច្បាប់ណាដែលយល់ថាអាចអនុវត្តបាន ក្នុងករណីណាដែលភាគី វិវាទមិនបានធ្វើការកំណត់លើប្រព័ន្ធច្បាប់នោះ។[21] លើសពីនេះទៅទៀត ការសម្រេចរបស់វេទិការមជ្ឈត្តកម្មត្រូវយកចិត្តទុកដាក់ "ដល់ទំលាប់ពាណិជ្ជកម្ម"។[22] តាមរយៈការបកស្រាយមាត្រាខាងលើបង្ហាញថា ច្បាប់ផ្សេងៗទៀតរបស់កម្ពុជាគួរតែយកមកបកស្រាយ និងពន្យល់បន្ថែមដើម្បីជួយកំណត់ពីអត្ថិភាពនៃសញ្ញាណ "ពាណិជ្ជកម្ម"។

ច្បាប់ស្តីពី វិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម បានកំណត់"ពាណិជ្ជករ" ថាជា "រូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលធ្វើពាណិជ្ជកិច្ចហើយដែលយកពាណិជ្ជកិច្ចនេះជាមុខរបរខ្លួនជាប្រចាំ"។[23] ចំណែក "ពាណិជ្ជកិច្ច" ជា"សកម្មភាពទិញលក់ទំនិញ ឬសេវាដែលត្រូវបានអនុវត្តជាប្រចាំ ក្នុងគោលដៅធ្វើការដោះដូរ និងស្វែករកចំណេញ"។[24] រីឯច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មមិនបានកំណត់ពីអញ្ញត្តកម្មសកម្មភាពដែលចាត់ទុកថា មិនមែនពាណិជ្ជកម្មឡើយ ហើយក៏មិនបានកំណត់ថា ទំនាក់ទំនងរវាងស្ថាប័នពាណិជ្ជកម្ម និងបុគ្គលអាចក្លាយជាកម្មវត្ថុនៃសម្រេចសេចក្តីដែរឬទេ។ មាត្រា២(ឈ) ផ្តោតលើសកម្មភាពដែលជាទំនាក់ទំនងពាណិជ្ជកម្មជាជាងការកំណត់ពីលក្ខខណ្ឌរបស់ពាណិជ្ជករ។ ដូច្នេះ ការបកស្រាយទូលាយ និងកង្វះខាតការផ្តល់និយមន័យ "ពាណិជ្ជកម្ម" ពេញលេញក្នុងច្បាប់នេះ ច្បាប់ដទៃទៀតត្រូវប្រើជាការណែនាំដល់វេទិការមជ្ឈត្តកម្មពាណិជ្ជកម្មក្នុងការសម្រេចពីដែនកំណត់នៃទំនាក់ទំនងរបស់គូភាគី។

លើសពីនេះទៅទៀត ច្បាប់ស្តីពីមជ្ឈត្តការពាណិជ្ជកម្មមិនបានចែងពីអញ្ញត្រកម្មលើចំណុចដែលមិនអាចដោះស្រាយបានឡើយ តែមាត្រា១(២) នៃច្បាប់នេះបានកំណត់ពីដែនសមត្ថកិច្ចក្នុងការសម្រេចរបស់ខ្លួនមិនឱ្យមានអន្តរាគមន៍ពីតុលាការតាមរយៈច្បាប់ដទៃទៀត។ នេះជាចំណុចសំខាន់មួយដើម្បីពិចារណា ពេលវេទិការពាណិជ្ជកម្មសម្រេចពីយុត្តាធិការរបស់ខ្លួន ប៉ុន្តែទាមទារឱ្យពិនិត្យមើលច្បាប់ដទៃទៀតដើម្បីពិចារណាពីដែនសមត្ថកិច្ចលើចំណុចវិវាទនោះ។ ដើម្បីជាការណែនាំក្នុងការកំណត់សញ្ញាណមិនមែនពាណិជ្ជកម្ម គួរតែយកបទពិសោធន៍ពីច្បាប់ប្រទេសនានាមកប្រៀបធៀបជាគំរូ។

---

[21] ច្បាប់ស្តីពីមជ្ឈការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ មាត្រា៣៦(២)។

[22] ច្បាប់ស្តីពីមជ្ឈការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ មាត្រា៣៦(៤)។

[23] ច្បាប់ស្តីពី វិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ មាត្រា១។

[24] ដូចខាងលើ។

ចំពោះការកំណត់សញ្ញាណមិនមែនពាណិជ្ជកម្មតុលាការ សាលាឧទ្ធរណ៍នៅប្រទេសសឹង្ហបុរីបានចេញសេចក្ដីសម្រេចមួយក្នុងឆ្នាំ២០១១ ពីកម្មវត្ថុដែលវេទិកាមជ្ឈត្តកម្មមិនអាចសម្រេចបាន ដោយសារតែប៉ះពាល់ដល់ប្រយោជន៍សាធារណៈរួមមាន៖

- បញ្ហាដែលទាក់ទងនឹងពលរដ្ឋ ឬភាពស្របច្បាប់នៃអាពាហ៍ពិពាហ៍
- ការផ្ដល់ជូន អាជ្ញាប័ណ្ណនានា តាមផ្លូវច្បាប់
- សុពលភាពនៃការចុះ ពាណិជ្ជនាម ឬប៉ាតង់
- សិទ្ធិថតចម្លង
- ការជម្រះក្ដីក្រុមហ៊ុន
- ក្ស័យធនរបស់កូនបំណុល
- ការគ្រប់គ្រងលើទ្រព្យសម្បត្តិ

រីឯក្រមរដ្ឋប្បវេណី និងពាណិជ្ជកម្មឆ្នាំ២០១៥ នៃប្រទេសអាហ្សង់ទីនដែលជាប្រទេសប្រព័ន្ធច្បាប់ស៊ីវិលដូចកម្ពុជាបានកំណត់ពីបញ្ហាមួយចំនួន ដែលវេទិកាមជ្ឈត្តកម្មមិនអាចសម្រេចបានរួមមាន៖

- ឋានៈស៊ីវិល ឬសមត្ថភាពរបស់បុគ្គល
- បញ្ហាគ្រួសារ
- អ្នកប្រើប្រាស់ និងអតិថិជន
- កិច្ចសន្យាតាមទម្រង់គំរូ
- ច្បាប់ការងារ
- ភាគីដែលជាសហព័ន្ធ ឬរដ្ឋក្នុងស្រុកទាំងឡាយ

ជារួមមក ដោយសារប្រទេសកម្ពុជាជាប្រទេសច្បាប់ស៊ីវិល លទ្ធភាពក្នុងការបកស្រាយច្បាប់ដែលខ្វះចន្លោះ ពុំអាចបត់បែនដូចប្រទេសកុំមិនឡទេ។ ទោះបីការកំណត់និយមន័យ ពាណិជ្ជកម្មក្នុងន័យទូលាយ ងាយស្រួលក្នុងការចាត់ថ្នាក់ចំណុចវិវាទឱ្យចូលដែនសមត្ថកិច្ចរបស់វេទិកាមជ្ឈត្តកម្ម ផលលំបាកនឹងកើតមានចំពោះទំនាស់តូចតាច។ ពេលដែលច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មបច្ចុប្បន្ន មិនបានចែងពីអត្ថសញ្ញាណកម្មលើទំនាស់ដែលមិនអាចដោះស្រាយបាន វេទិកាមជ្ឈត្តកម្មនឹងត្រូវសម្រេចដោយខ្លួនឯងពីយុត្តិការលើចំណុចវិវាទ និងផ្អែកលើការបកស្រាយច្បាប់ក្នុងស្រុកមួយចំនួន ដើម្បីកំណត់ពីសញ្ញាណពាណិជ្ជកម្ម។

### ១.៥.២ កិច្ចព្រមព្រៀងផ្សះផ្សា

ភាគីត្រូវធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរដោយភាគីព្រមព្រៀងថានឹងប្រើវេទិការមជ្ឈត្តកម្ម ពាណិជ្ជកម្ម។ កិច្ចព្រមព្រៀងផ្សះផ្សារួមមានខចែងស្តីមជ្ឈត្តការដែលបានចែងក្នុងកិច្ចសន្យា ឬ ក្នុងកិច្ចព្រមព្រៀងដោយឡែក។[25] មានន័យថា ក្នុងករណីដែលមានខចែងស្តីពីមជ្ឈត្តការដែលត្រូវបានសរសេរជាលាយលក្ខណ៍អក្សរនៅក្នុងកិច្ចសន្យារបស់គូភាគី ឬបើគូភាគីព្រមព្រៀងធ្វើមជ្ឈត្តការនក្នុងកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរដាច់ដោយឡែកមួយពីកិច្ចសន្យា នោះវិវាទពាណិជ្ជកម្មត្រូវតែដោះស្រាយតាមមជ្ឈត្តការ។ កិច្ចព្រមព្រៀងចាំបាច់ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ប៉ុន្តែលក្ខខណ្ឌតម្រូវនេះអាចបំពេញបាន ដោយការសរសេរលិខិតឆ្លើយតបគ្នាទៅវិញទៅមកដែលបង្ហាញឱ្យឃើញពីឆន្ទៈទទួលយកការធ្វើមជ្ឈត្តការ។[26]

ឧទាហរណ៍៖ ភាគីអាចផ្ញើរអ៊ីមែល ឬលិខិតឆ្លើយឆ្លងគ្នា ដែលបញ្ជាក់ថាពួកគេពិតជាមានបំណងទទួលយកដំណោះស្រាយវិវាទរបស់ផងខ្លួនតាមរយៈមជ្ឈត្តការ ប៉ុន្តែខកខានមិនបានបញ្ចូលខចែងនោះក្នុងកិច្ចសន្យាគោលរបស់ពួកគេ។

### ១.៥.៣ មូលដ្ឋានក្នុងកិច្ចសន្យា

ជាទូទៅ គូភាគីយល់ព្រមទទួលយកដំណោះស្រាយដោយមជ្ឈត្តការ នៅពេលចុះហត្ថលេខាលើកិច្ចសន្យាគោលរបស់ខ្លួន។ ដើម្បីដោះស្រាយវិវាទរបស់ខ្លួនតាមរយៈមជ្ឈត្តការ គូភាគីចាំបាច់ត្រូវមានខចែងស្តីពីមជ្ឈត្តការដែលមានសុពលភាព និងអាចអនុវត្តបាននៅក្នុងកិច្ចសន្យារបស់ខ្លួន។

ដើម្បីឱ្យខចែងមានសុពលភាព ខចែងនោះត្រូវសរសេរជាលាយលក្ខណ៍អក្សរ ហើយមានភាពច្បាស់លាស់។ ប្រការនេះមានន័យថា ខចែងស្តីពីមជ្ឈត្តការត្រូវបញ្ជាក់ច្បាស់ថា គូភាគីចង់ដោះស្រាយដោយមជ្ឈត្តការក្នុងករណីមានវិវាទកើតឡើង។ គួរបញ្ជាក់ថា បើខចែងស្តីពីមជ្ឈត្តការជាផ្នែកមួយនៃកិច្ចសន្យា ខចែងស្តីពីមជ្ឈត្តការនោះ ត្រូវចាត់ទុកជាការកិច្ចព្រមព្រៀងដោយឡែក ដែលមិនទាក់ទងនឹង លក្ខខណ្ឌ និងខចែងនៃកិច្ចសន្យាផ្សេងឡើយ ហើយបើវេទិការមជ្ឈត្តកម្មចាត់ទុកកិច្ចសន្យាជាមោឃៈ ក៏ខចែងស្តីពីមជ្ឈត្តការនៅតែមានសុពលភាព។[27] ឧទាហរណ៍៖ បើគូភាគីបញ្ចូលគំរូខចែងពីមជ្ឈត្តការរបស់ ម.ជ.ម. ទៅក្នុងកិច្ចសន្យាមូលដ្ឋាន

---

[25] ច្បាប់ស្តីពីមជ្ឈការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ មាត្រា៧។

[26] ដូចខាងលើ។

[27] វិធានស្តីមជ្ឈការពាណិជ្ជកម្មរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១៤ ចំណុច១៩.៣ និងច្បាប់ស្តីពីមជ្ឈការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ មាត្រា២៤។

រាល់វិវាទទាំងអស់ដែលកើតចេញពី ឬដែលទាក់ទងនឹងកិច្ចសន្យានេះ រួមបញ្ចូលវិវាទទាំងឡាយដែលពាក់ព័ន្ធនឹងអត្ថិភាព សុពលភាព ការអនុវត្ត ឬការបញ្ចប់កិច្ចសន្យានេះ ត្រូវបញ្ចូលទៅដោះស្រាយជាស្ថាពរតាមរយៈមជ្ឈត្តការ នៅមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នៅព្រះរាជាណាចក្រកម្ពុជា ស្របតាមវិធានស្ដីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (វិធាន ម.ជ.ម.) ដែលមានសុពលភាពអនុវត្ត នៅពេលចាប់ផ្ដើមដំណើរការមជ្ឈត្តការហើយតាមរយៈការយោងប្រការនេះ វិធាន ម.ជ.ម. ត្រូវចាត់ទុកថាបានរួមបញ្ចូលជាផ្នែកមួយនៃកិច្ចសន្យានេះ។

វេទិការមជ្ឈត្តកម្មត្រូវមានមជ្ឈត្តករចំនួន………………….នាក់។

(ចំនួនមជ្ឈត្តករត្រូវកំណត់ជាចំនួនសេស)

ភាសានៃមជ្ឈត្តការគឺ…………………………………….។

ច្បាប់ដែលត្រូវយកមកអនុវត្តកិច្ចសន្យានេះត្រូវស្ថិតក្រោមបញ្ញត្តិច្បាប់នៃ…………………..**។

(**បញ្ជាក់ឈ្មោះប្រទេស ឬយុត្តាធិការ)

ប៉ុន្តែក្រៅពីលក្ខខណ្ឌតម្រូវទាំងនេះ គូភាគី ឬមេធាវីរបស់ពួកគេអាចបន្ថែមចំណុចលម្អិតសំខាន់ៗ ទៅក្នុងខចែងស្ដីពីមជ្ឈត្តការ។ ក្នុងស្ថានភាពមួយចំនួន ខចែងស្ដីពីមជ្ឈត្តការមូលដ្ឋានគឺ គ្រប់គ្រាន់ហើយ ប៉ុន្តែក្នុងស្ថានភាពខ្លះ ចំណុចលម្អិតមួយចំនួនចាំបាច់ត្រូវតែបន្ថែម។ ខចែងស្ដីពីមជ្ឈត្តការមានសារៈសំខាន់ក្នុងការចាប់ផ្ដើមមជ្ឈត្តការ ដូច្នេះពេលបង្កើតខចែងស្ដីពីមជ្ឈត្តការមូលដ្ឋានក្នុងកិច្ចសន្យា គូភាគីត្រូវពិចារណាពីបញ្ហាគន្លឹះមួយចំនួនដែលអាចកើតមានក្នុងដំណើរការមជ្ឈត្តការដូចជា៖

- **ប្រភេទមជ្ឈត្តការ**

កត្តាសំខាន់ដែលគូភាគីជ្រើសរើសយកមជ្ឈត្តការដើម្បីដោះស្រាយវិវាទ ព្រោះតែវាផ្ដល់ភាពឆាប់រហ័ស និងមានប្រសិទ្ធភាព។ បើមជ្ឈត្តការមិនចងភ្ជាប់កាតព្វកិច្ចទេនោះ ភាគីមិនអាចទទួលបានមជ្ឈត្តវិនិច្ឆ័យស្ថាពរឡើយ ពោលមជ្ឈត្តវិនិច្ឆ័យនោះ គ្រាន់តែជាអនុសាសន៍ដែលផ្ដល់ឱ្យគូភាគីដូចនឹងដំណើរការសន្ទានកម្មដូច្នោះដែរ។ ករណីនេះ ដំណើរការមិនអាចមានភាពឆាប់រហ័ស និងមានប្រសិទ្ធភាពឡើយ។ ជាទូទៅ គូភាគីជ្រើសយកមជ្ឈត្តការពិសេស ព្រោះវាផ្ដល់ឱ្យគូភាគីនូវភាពបត់បែនច្រើនក្នុងការបង្កើតនីតិវិធី និងវិធានដែលតម្រូវនឹងវិវាទ។ គូភាគីក៏អាចជ្រើសយកមជ្ឈត្តការមានការគ្រប់គ្រង ដោយសារតែមជ្ឈត្តការមានការគ្រប់គ្រងមានការគាំទ្រយ៉ាងទូលាយ ផ្ដល់ជម្រើសច្រើនលើមជ្ឈត្តករដែលនឹងមកដោះស្រាយវិវាទ និងមានវិធានគ្រប់គ្រងស្រាប់ដែលគូភាគីអាចជ្រើសរើសបានយ៉ាងឆាប់រហ័ស។ នៅពេលចុះកិច្ចសន្យា គូភាគីជាច្រើនចង់សន្សំសំចៃកម្លាំង និងពេលវេលា ទើបគូភាគីជ្រើសយកមជ្ឈមណ្ឌលមជ្ឈត្តការចម្បងណាមួយដែលមានការគ្រប់គ្រង។

- **ទីកន្លែងមជ្ឈត្តការ**

ទីកន្លែងសម្រាប់ដំណើរការមជ្ឈត្តការមានសារៈសំខាន់ណាស់ ជាពិសេសចំពោះវិវាទអន្តរជាតិ។ ទីកន្លែងអាចកំណត់ពីថ្លៃចំណាយនៃដំណើរមជ្ឈត្តការ។

ឧទាហរណ៍៖ បើគូភាគី សាក្សី ភស្តុតាង ឯកសារ។ល។ នៅឆ្ងាយ នោះដំណើរការដោះស្រាយវិវាទនឹងមានតម្លៃថ្លៃខ្លាំង។ ទីកន្លែងក៏អាចកំណត់ថា តុលាការជាតិណាមួយនឹងមានយុត្តាធិការទៅលើដំណើរការមជ្ឈត្តការនោះ។ លើសពីនេះទៀត គូភាគីត្រូវពិចារណាពីកន្លែងនៃបណ្តុំមជ្ឈត្តករដែលមានសមត្ថភាព និងអព្យាក្រឹត។ ជាចុងក្រោយ ទីកន្លែងអាចមានឥទ្ធិពលលើការអនុវត្តមជ្ឈត្តវិនិច្ឆ័យ។ បើទីកន្លែងស្ថិតនៅក្នុងប្រទេសដែលមិនមែនជាហត្ថលេខីនៃអនុសញ្ញាក្រុងញូវយ៉ក នោះមជ្ឈត្តវិនិច្ឆ័យប្រឈមនឹងបញ្ហាពេលដាក់ឱ្យអនុវត្ត។

- **ចំនួនមជ្ឈត្តករ**

ចំនួនមជ្ឈត្តករអាចមានម្នាក់ ឬបីនាក់។ ជាទូទៅ ភាគីនីមួយៗត្រូវជ្រើសរើសមជ្ឈត្តករម្នាក់មួយៗ ហើយមជ្ឈត្តករទាំងពីរនាក់នោះត្រូវជ្រើសរើសមជ្ឈត្តករទីបីម្នាក់។ ផ្អែកតាមការជ្រើសរើសនេះ គូភាគីអាចកំណត់បុគ្គលជាក់លាក់ណាមួយក្នុងខចែងស្តីពីមជ្ឈត្តការ តែវាមានភាពប្រថុយប្រថានត្រង់ថា គេអាចរកបុគ្គលនោះមិនបាន បើវិវាទកើតឡើងនៅច្រើនឆ្នាំក្រោយមក។ គូភាគីក៏អាចកំណត់ប្រភេទបុគ្គលដែលនឹងមកធ្វើជាមជ្ឈត្តករផងដែរ ដូចជាចៅក្រមឬពលរដ្ឋកម្ពុជា។

- **ការចរចា ឬសន្ធានកម្មមុនដំណើរការមជ្ឈត្តការ**

ពេលខ្លះភាគីត្រូវព្យាយាមធ្វើការចរចា ឬធ្វើសន្ធានកម្មជាមុនសិនមុនពេលឈានដល់ដំណើរការមជ្ឈត្តការ។ គូភាគីអាចនឹងទទួលផលប្រយោជន៍ពីកិច្ចខិតខំប្រឹងប្រែងនេះ មុនពេលដាក់វិវាទទៅកាន់ដំណើរការដែលប្រកបដោយភាពបដិបក្ខគ្នា ដូចជាមជ្ឈត្តការជាដើម។ វិធីម្យ៉ាងទៀត គូភាគីអាចធ្វើសន្ធានកម្មជាមុន ហើយបើសន្ធានកម្មនោះមិនទទួលបានជោគជ័យ ទើបចាប់ផ្តើមធ្វើមជ្ឈត្តការជាក្រោយ។ ច្បាប់កម្ពុជាស្តីពីមជ្ឈត្តការពាណិជ្ជកម្ម ពិចារណាយ៉ាងច្បាស់ពីលទ្ធភាពនេះ នៅក្នុងមាត្រា៣៨ ដែលស្ថិតនៅក្រោមផ្នែកស្តីពី "ដំណោះស្រាយ" ។[28] ចំពោះករណីធំៗ និងស្មុគស្មាញ មជ្ឈត្តការសន្ធាន ជានិច្ចកាលតែងមានភាគី ជាប់ពាក់ព័ន្ធច្រើនជាងពីរ។

ឧទាហរណ៍៖ ករណីពាក់ព័ន្ធនឹងការសាងសង់ គូភាគីអាចរាប់បញ្ចូលទាំងម្ចាស់អចលនទ្រព្យ ធនាគារដែលផ្តល់ប្រាក់កម្ចីឱ្យកម្មសិទ្ធិករ ក្រុមហ៊ុនម៉ៅការសំណង់ទូទៅ ក្រុមហ៊ុនម៉ៅការសំណង់បន្ត ដែលត្រូវបានជួល

[28] ច្បាប់ស្តីពីមជ្ឈការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ មាត្រា៣៨។

ដោយក្រុមហ៊ុនម៉ៅការទូទៅ អ្នកផ្គត់ផ្គង់សម្ភារៈ និងអាចជាក្រុមហ៊ុនដែលមានផែនការជួលទីតាំងកម្មសិទ្ធិករក្រោយពេលសាងសង់ចប់រួចផងដែរ។ ក្នុងស្ថានភាពនេះ ការប្រមូលផ្តុំវិវាទបញ្ចូលគ្នា នឹងធ្វើឱ្យគូភាគីចំណេញពេលវេលា និងប្រាក់កាស ។

- **កម្រិតនៃតម្រូវការឱ្យភាគីបង្ហាញព័ត៌មាន**

ក្នុងប្រព័ន្ធតុលាការមួយចំនួន ដូចជានៅក្នុងសហរដ្ឋអាមេរិកជាដើម ការបង្ហាញព័ត៌មានលម្អិតមុនសវនាការ ដូចជាឯកសារ និងសេចក្តីអំណះអំណាងរបស់សាក្សី និងភាគីវិវាទផ្ទាល់ ជាលក្ខខណ្ឌតម្រូវចំពោះគូភាគី។ នៅក្នុងប្រព័ន្ធច្បាប់កុំមិនឡ ហៅដំណើរការនេះថា"ការផ្លាស់ប្តូរព័ត៌មាន"។ ប៉ុន្តែ ប្រព័ន្ធច្បាប់ស៊ីវិលដូចជា នៅប្រទេសបារាំងជាដើម លក្ខខណ្ឌតម្រូវក្នុងការចែករំលែកព័ត៌មានមានលក្ខណៈរឹតត្បឹតជាង។ ស្រដៀងគ្នានេះ ក្នុងវិធានមជ្ឈត្តការភាគច្រើន លក្ខខណ្ឌតម្រូវនៃការបង្ហាញព័ត៌មានមុនសវនាការក៏មានភាពរឹតត្បឹតដែរ។ ទោះជាយ៉ាងនេះក្តី គូភាគីក៏អាចកំណត់ពីកម្រិតនៃកាបង្ហាញព័ត៌មានមុនសវនាការដែរ។

- **សមត្ថកិច្ចរបស់មជ្ឈត្តករក្នុងការដោះស្រាយវិវាទ**

គូភាគីត្រូវកំណត់ពីចំណុចវិវាទជាក់លាក់ និងដំណោះស្រាយដែលពួកគេចង់ឱ្យមជ្ឈត្តករសម្រេច។

- **ច្បាប់គ្រប់គ្រងដំណើរការ**

គូភាគីត្រូវកំណត់ពីច្បាប់ចម្បងដែលគ្រប់គ្រងដំណើរការនេះ ហៅថា"បញ្ញត្តិស្តីពីជម្រើសនៃច្បាប់"។ គូភាគីត្រូវដឹងពីប្រការនេះនៅគ្រប់ពេលចុះកិច្ចសន្យា។ ពុំនោះទេ ករណីមានវិវាទកើតឡើង បទបញ្ញត្តិរបស់តុលាការ ឬស្ថាប័នមជ្ឈត្តការដែលស្តីពីទំនាស់នៃបញ្ញត្តិនឹងត្រូវប្រើដើម្បីកំណត់ថា ច្បាប់ណាមួយដែលនឹងត្រូវយកមកអនុវត្ត។ ការធ្វើដូច្នេះបង្កើតនូវភាពមិនច្បាស់លាស់សម្រាប់ភាគី។ ជាលទ្ធផល បញ្ញត្តិស្តីពីជម្រើសនៃច្បាប់តែងតែត្រូវបានបញ្ចូលក្នុងកិច្ចសន្យាស្ទើរតែទាំងអស់។

- **វិធានគ្រប់គ្រងដំណើរការ**

គូភាគីមានសេរីភាពទាំងស្រុងក្នុងការកំណត់វិធានគ្រប់គ្រងនីតិវិធី។ គូភាគីអាចតាក់តែងវិធានផ្ទាល់របស់ខ្លួន តែករណីនេះមិនសូវមានឡើយ ដោយសារតែកម្រិតនៃការយល់ដឹងច្បាប់របស់គូភាគី ហើយមជ្ឈមណ្ឌលមជ្ឈត្តការភាគច្រើនមានវិធានគ្រប់គ្រងនីតិវិធីជាច្រើនសម្រាប់ឱ្យជ្រើសរើស។ មជ្ឈមណ្ឌលមជ្ឈត្តការភាគច្រើន អនុញ្ញាតឱ្យគូភាគីប្រើប្រាស់វិធានរបស់មជ្ឈមណ្ឌលមជ្ឈត្តការដទៃ។

ឧទាហរណ៍៖ គូភាគីជ្រើសយកមជ្ឈមណ្ឌលមជ្ឈត្តការជាតិកម្ពុជាធ្វើជាអ្នកគ្រប់គ្រង ប៉ុន្តែអាចប្រើវិធានមជ្ឈត្តការគំរូរបស់មជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិសិង្ហបុរីបាន ហើយថែមទាំងអាចកែប្រែនីតិវិធីខ្លះដើម្បីបំពេញតម្រូវការពិសេសរបស់ខ្លួន ដូចជាការពន្លឿននីតិវិធីជាដើម។

- **ភាសាត្រូវប្រើក្នុងដំណើរការ**

នៅក្នុងកិច្ចសន្យាដែលមានការចូលរួមពីគូភាគីអន្តរជាតិ ការបញ្ចូលបញ្ញត្តិដែលចែងពីភាសាដែលត្រូវប្រើក្នុងដំណើរការមជ្ឈត្តការ ពិតជាមានសារសំខាន់ណាស់។

- **ការសម្ងាត់នៃដំណើរការ**

ដំណើរការមជ្ឈត្តការត្រូវបានរក្សាជាការសម្ងាត់ ហើយមជ្ឈមណ្ឌលមជ្ឈត្តការធំៗភាគច្រើនតែងរក្សាការសម្ងាត់។ ប៉ុន្តែបើភាគីព្រួយបារម្ភខ្លាំងពីការសម្ងាត់ ឬបើពួកគេកំពុងតាក់តែងវិធានមជ្ឈត្តការពិសេសផ្ទាល់ខ្លួន ពួកគេអាចនឹងចង់សង្កត់ធ្ងន់លើចំណុចនេះនៅក្នុងកិច្ចព្រមព្រៀងរបស់ខ្លួន។ លើសពីនេះទៀត គូភាគអាចកែប្រែភាសាដើម្បីរឹតត្បឹតការផ្សព្វផ្សាយកម្មវត្ថុមួយចំនួនដូចជា រឹតត្បឹតការផ្សព្វផ្សាយការសម្ងាត់ពាណិជ្ជកម្មផ្សេងៗជាដើម។

- **ការពន្យល់ជាលាយលក្ខណ៍របស់មជ្ឈត្តករ**

មជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិភាគច្រើនមានវិធានដែលទាមទារឱ្យវេទិការមជ្ឈត្តកម្មរៀបចំសេចក្តីសម្រេចដែលភ្ជាប់ជាមួយហេតុផល។ ប៉ុន្តែមជ្ឈមណ្ឌលមជ្ឈត្តការជាតិមួយចំនួន ពុំមានលក្ខខណ្ឌតម្រូវបែបនេះទេ។ គុណសម្បត្តិម្យ៉ាងនៃសេចក្តីសម្រេចដែលបញ្ជាក់ហេតុផល គឺគូភាគីអាចយល់កាន់តែច្បាស់ពីសេចក្តីសម្រេច ហើយអាចតវ៉ាពីការលម្អៀង ឬភាពអយុត្តិធម៌នៃលទ្ធផល។ រីឯគុណវិបត្តិ គឺវានឹងក្លាយជាមូលដ្ឋានសក្តានុភូតមួយសម្រាប់ការពិនិត្យឡើងវិញរបស់តុលាការក្នុងករណីភាគីម្ខាងចង់គេចវេសពីសេចក្តីសម្រេច។

- **ភាគីទទួលបន្ទុកបង់ថ្លៃចំណាយ**

ភាគីវិវាទត្រូវបង់ថ្លៃមេធាវី និងចំណាយផ្ទាល់ខ្លួននៅពេលពួកគេទូទាត់វិក្កយបត្រមជ្ឈត្តការ តែបើគូភាគីចង់ជម្រុញឱ្យមានដំណោះស្រាយមុនពេលធ្វើមជ្ឈត្តការ ពួកគេអាចយល់ព្រមប្រគល់ថ្លៃមេធាវី ថ្លៃចំណាយ និងវិក្កយបត្រមជ្ឈត្តការឱ្យទៅភាគីដែលឈ្នះក្នុងដំណើរការមជ្ឈត្តការ។ ការបញ្ចូលបញ្ញត្តិនេះក្នុងកិច្ចព្រមព្រៀងផ្សះផ្សានាំឱ្យមជ្ឈត្តការកាន់តែមានភាពប្រថុយប្រថានសម្រាប់គូភាគីនឹងជម្រុញឱ្យឆាប់មានដំណោះស្រាយ។

## ១.៦ គុណសម្បត្តិនិងគុណវិបត្តិនៃមជ្ឈត្តការ

### ១.៦.១ គុណសម្បត្តិនៃមជ្ឈត្តការ

- **ថ្លៃចំណាយ៖** មជ្ឈត្តការប្រើចំណាយតិចជាងបណ្តឹងទៅតុលាការព្រោះមជ្ឈត្តការ មានភាពរលូនជាងនីតិវិធីទៅតុលាការ ជាពិសេសការប្តឹងឧបាស្រ័យមជ្ឈត្តវិនិច្ឆ័យមានភាពរឹតត្បឹត។
- **ល្បឿន៖** មជ្ឈត្តការដោះស្រាយវិវាទបានឆាប់រហ័សជាងដំណើរការបណ្តឹងទៅតុលាការ ដោយសារតែការប្តឹងឧបាស្រ័យមានលក្ខណៈរឹតត្បឹត។ ផ្ទុយមកវិញ ចំពោះដំណើរការបណ្តឹងតុលាការ ភាគីអាចប្តឹងឧបាស្រ័យយ៉ាងហោចណាស់ម្តង ឬច្រើនដង។ លើសពីនេះទៀត ប្រព័ន្ធតុលាការមានរឿងក្តីដែលរងចាំការដោះស្រាយជាច្រើន ដែលនាំឱ្យគូភាគីត្រូវរង់ចាំយូរទើបទទួលបានការដោះស្រាយ។
- **លក្ខណៈស្ថាពរ៖** សេចក្តីសម្រេចរបស់មជ្ឈត្តករមានលក្ខណៈស្ថាពរ នេះជាប្រយោជន៍សម្រាប់គូភាគី។
- **ការដាក់ឱ្យអនុវត្តថ្នាក់ជាតិ៖** ដោយសារប្រទេសកម្ពុជាបានអនុម័តច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ខ្លួន តុលាការកម្ពុជាអាចដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យដោយផ្ទាល់។ រីឯដំណោះស្រាយតាមការចរចា ឬសន្ទានកម្ម មិនអាចដាក់ឱ្យអនុវត្តបានឡើយ។
- **ការដាក់ឱ្យអនុវត្តថ្នាក់អន្តរជាតិ៖** អនុលោមតាមអនុសញ្ញាក្រុងញូវយ៉កស្តីពីការទទួលស្គាល់ និងការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេស មជ្ឈត្តវិនិច្ឆ័យដែលធ្វើឡើងនៅក្នុងប្រទេសហត្ថលេខី អាចដាក់ឱ្យអនុវត្តបានដោយស្វ័យប្រវត្តិក្នុងបណ្តាប្រទេសហត្ថលេខីផ្សេងទៀតទាំងអស់។ ប្រការនេះ សំខាន់ណាស់សម្រាប់ដោះស្រាយវិវាទអន្តរជាតិ ព្រោះសេចក្តីសម្រេចរបស់តុលាការមិនអាចដាក់ឱ្យអនុវត្តជាអន្តរជាតិបែបនេះទេ។
- **ការរក្សាទំនាក់ទំនង៖** ទោះបីជាមជ្ឈត្តការមានភាពបដិបក្ខក៏ដោយ ក៏ភាពបដិបក្ខនោះតិចជាងដំណើរការបណ្តឹងនៅតុលាការ ដែលកត្តានេះអាចជួយរក្សាទំនាក់ទំនងរវាងភាគីបាន។
- **ភាពជាឯកជន៖** ផ្ទុយពីដំណើរការបណ្តឹងនៅតុលាការ ជាទូទៅ ដំណើរការមជ្ឈត្តការមានភាពជាឯកជន ដែលនេះជាគុណសម្បត្តិដ៏ធំចំពោះគូភាគីដែលមិនចង់ឱ្យសាធារណៈជនដឹងពីចំណុចលម្អិតនៃវិវាទរបស់ពួកគេ។
- **ដំណោះស្រាយដែលអាចបត់បែនបាន៖** មជ្ឈត្តករអាចបត់បែនក្នុងការសម្រេចលើមធ្យោបាយ ដោះស្រាយដែលប្រកបដោយភាពច្នៃប្រឌិត រីឯតុលាការមិនអាចធ្វើបានឡើយ។
  ឧទាហរណ៍៖ ការសម្រេចឱ្យភាគីចាញ់ក្តីចេញថ្លៃមេធាវី។

- **មជ្ឈត្តករមានជំនាញនិងវិជ្ជាជីវៈ៖** គូភាគីអាចជ្រើសយកមជ្ឈត្តករដែលមានជំនាញនៅក្នុងវិស័យអាជីវកម្ម ដែលត្រូវនឹងវិស័យការងាររបស់ពួកគេ។
  ឧទាហរណ៍៖ នៅក្នុងវិស័យកសិកម្ម ឬមួយបច្ចេកទេសជាដើម ។ ម្យ៉ាងទៀតប្រព័ន្ធតុលាការភាគច្រើនពុំមានចៅក្រមជំនាញសម្រាប់វិស័យនៃច្បាប់ណាមួយជាក់លាក់ទេ ដែលធនាំឱ្យភាគីវិវាទអាចត្រូវមានចៅក្រមណាម្នាក់ ដែលគ្មានចំណេះដឹងជាក់លាក់ពីវិស័យអាជីវកម្មរបស់ខ្លួន ។ ហេតុនេះ ករណីដែលចំណេះដឹងជាក់លាក់ពីវិស័យអាជីវកម្ម ឬច្បាប់មានភាពសំខាន់ ដំណើរការមជ្ឈត្តការអាចផ្តល់លទ្ធផលកាន់តែត្រឹមត្រូវ។
- **នីតិវិធីដែលអាចបត់បែនបាន៖** ភាគីអាចលំណត់នីតិវិធី ដែលខ្លួនចង់បានដូចជា លក្ខណៈស្មុគស្មាញដូចដំណើរការបណ្ដឹងនៅតុលាការ ឬនីតិវិធីដែលមានលក្ខណៈសាមញ្ញជាងនេះ។ ក្នុងបណ្ដឹងតុលាការគូភាគី ត្រូវតែគោរពតាមនីតិវិធីច្បាប់ ទោះបីជាពួកគេមិនពេញចិត្តនឹងនីតិវិធីនោះក៏ដោយ។ នេះជាមូលហេតុចម្បងដែលក្រុមហ៊ុនអន្តរជាតិជ្រើសយកមធ្យោបាយមជ្ឈត្តការ។
- **អព្យាក្រឹត្យភាពរបស់មជ្ឈត្តករ៖** គូភាគីនៃវិវាទអន្តរជាតិ តែងព្រួយបារម្ភថាចៅក្រមនៃតដ្ឋភាគីម្ចាស់ផ្ទះអាចមានភាពលម្អៀងទៅលើភាគីនោះ ហៅថា"គុណសម្បត្តិនៃតុលាការលំនៅ"។ មជ្ឈត្តការអាចលុបបំបាត់ភាពលម្អៀងលើជាតិសាសន៍ដែលអាចកើតមាន។

**១.៦.២ គុណវិបត្តិនៃមជ្ឈត្តការ**

- **ចំណាយ៖** ទោះបីជាការចំណាយលើមជ្ឈត្តការទាបជាងដំណើរការបណ្ដឹងនៅតុលាការក៏ដោយ មជ្ឈត្តការនៅតែអាចមានតម្លៃថ្លៃដដែល។ គូភាគីត្រូវចំណាយលើពេលវេលារបស់មជ្ឈត្តករ បន្ទប់សវនាការ ថ្លៃវេទិការធ្វើមជ្ឈត្តការ ព្រមទាំងថ្លៃដំណើរការកាត់ក្ដីធម្មតាផ្សេងៗទៀតដូចជាថ្លៃជួលមេធាវី និងថ្លៃចំណាយដែលពាក់ព័ន្ធដទៃទៀត ដែលដំណើរការនេះមានតម្លៃថ្លៃជាងការចរចា និងសន្ទានកម្ម។
- **ល្បឿន៖** ទោះបីជាមជ្ឈត្តការផ្ដល់នូវដំណោះស្រាយវិវាទឆាប់រហ័សជាងដំណើរការបណ្ដឹងតុលាការ ក៏មជ្ឈត្តការអាចមានល្បឿនយឺតជាងការចរចា និងសន្ទានកម្ម។ គូភាគីត្រូវប្រើពេលវេលាច្រើនដើម្បីរៀបចំរឿងក្ដីរបស់ខ្លួនសម្រាប់ធ្វើមជ្ឈត្តការ ខុសពីសន្ទានកម្ម និងការចរចា។
- **អនុលោមភាពមានកម្រិតទាប៖** ដោយសារមជ្ឈត្តវិនិច្ឆ័យមិនមែនជាលទ្ធផលនៃការចរចា ឬការសម្រួលគ្នា ដូច្នេះវាអាចនាំឱ្យមជ្ឈត្តវិនិច្ឆ័យគ្មានអនុលោមភាព ដែលបណ្ដាលឱ្យគូភាគីត្រូវចំណាយចាំបាច់បន្ថែមកាន់តែច្រើនលើថ្លៃមេធាវី ដើម្បីបន្តសុំការអនុវត្តតាមប្រព័ន្ធតុលាការ។

- **សវនាការជឯកជន៖** ក្នុងស្ថានភាពខ្លះ ភាគីម្ខាងចង់ឱ្យមានសវនាការជាសាធារណៈ ដើម្បីការពារប្រយោជន៍ខ្លួន និងប្រឆាំងនឹងការទាមទារ ឬដើម្បីដាក់ទណ្ឌកម្មលើភាគីម្ខាងទៀតឱ្យមានការអាម៉ាស់មុខជាសាធារណៈ។ ដោយសារតែមជ្ឈត្តការមិនអនុញ្ញាតឱ្យមានចំណុចនេះ ទើបវាអាចជាគុណវិបត្តិចំពោះគូភាគីក្នុងស្ថានភាពជាក់លាក់ណាមួយ។
- **ការរក្សាទំនាក់ទំនងរវាងគូភាគី៖** ទោះបីជាមជ្ឈត្តការអាចរក្សាទំនាក់ទំនងរបស់គូគីបានល្អជាងដំណើរការបណ្តឹងនៅតុលាការក៏ដោយ ទម្រង់នៃការដោះស្រាយវិវាទដូចជា ការចរចា និងសន្ធានកម្ម កាន់តែមានប្រសិទ្ធភាពក្នុងការរក្សាទំនាក់ទំនងរបស់គូភាគី។
- **មិនអាចព្យាករណ៏លទ្ធផល៖** ដោយសារមជ្ឈត្តករបំពេញតួនាទីជាអ្នកសម្របសម្រួល និងវិនិច្ឆ័យរឿងក្តីដោយផ្អែកលើគោលការណ៍សមភាព និងមិនចាំបាច់មានច្បាប់គ្រប់គ្រង នោះលទ្ធផលមានភាពមិនច្បាស់លាស់។

# ជំពូកទី២
# ដំណើរការនៃនីតិវិធីមជ្ឈត្តការពាណិជ្ជកម្ម

# ជំពូកទី២

# ដំណើរការនៃនីតិវិធីមជ្ឈត្តការពាណិជ្ជកម្ម

ទាក់ទិននឹងដំណើរការមជ្ឈត្តការនៅកម្ពុជា គូភាគីអាចព្រមព្រៀង ឬមិនព្រមព្រៀងពីនីតិវិធីដែលវេទិការមជ្ឈត្តការត្រូវអនុវត្តដើម្បីគ្រប់គ្រងដំណើរការមជ្ឈត្តការ។[29] ករណីគ្មានការព្រមព្រៀងពីនីតិវិធីទេ វេទិការមជ្ឈត្តការអាចចាត់ចែងដំណើរការមជ្ឈត្តការតាមបែបបទដែលខ្លួនយល់ថាសមស្រប។[30] ចំពោះដំណើរការមជ្ឈត្តការនៅកម្ពុជា បើគូភាគីជ្រើសយកមជ្ឈត្តការមានការគ្រប់គ្រង នោះដំណើរការមជ្ឈត្តការនឹងត្រូវគ្រប់គ្រងដោយ ម.ជ.ម.។ ដំណើរការមជ្ឈត្តការដែលគ្រប់គ្រងដោយ ម.ជ.ម. ត្រូវប្រព្រឹត្តទៅដោយអនុលោមតាមច្បាប់ស្ដីពីមជ្ឈត្តការពាណិជ្ជកម្ម និងវិធាន ម.ជ.ម.។ ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មជាច្បាប់ដែលចែងពីបទដ្ឋានមជ្ឈត្តការ។ ច្បាប់នេះគ្របដណ្ដប់លើគ្រប់ទិដ្ឋភាពនៃបញ្ហាមជ្ឈត្តការរួមមាន៖ កិច្ចព្រមព្រៀងផ្សះផ្សា សមាសភាព និងយុត្តាធិការរបស់វេទិការមជ្ឈត្តកម្ម ការដឹកនាំដំណើរការ ការទទួលស្គាល់ និងការអនុវត្តមជ្ឈត្តវិនិច្ឆ័យ។ គូភាគីអាចបង្វែរចេញពីបទដ្ឋាននេះ ជាពិសេសទាក់ទងនឹងជម្រើសវិធានមជ្ឈត្តការ។ វិធានមជ្ឈត្តការមានភាពខុសគ្នាបន្តិចបន្តួចពីវិធាននៃច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម តែច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មអនុញ្ញាតឱ្យភាគីធ្វើដូច្នេះបាន។ ករណីវិធានណាមួយនៃវិធាន ម.ជ.ម. ផ្ទុយនឹងបទប្បញ្ញត្តិដែលមានអានុភាពចាប់បង្ខំណាមួយរបស់ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នោះបទប្បញ្ញត្តិនោះត្រូវមានឧត្តមានុភាព។[31]

ឧទាហរណ៍៖ នៅកម្ពុជាបើភាគីជ្រើសរើសយក ម.ជ.ម. ធ្វើជាអ្នកគ្រប់គ្រងដំណើរការមជ្ឈត្តការរបស់ខ្លួន គូភាគីច្បាស់ជា ជ្រើសយកវិធានមជ្ឈត្តការរបស់ ម.ជ.ម.ដែរ តែពួកគេក៏អាចជ្រើសយកវិធានមជ្ឈត្តការផ្សេងដូចជា វិធានរបស់មជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិសិង្ហបុរីជាដើម។

គួរបញ្ជាក់ថា ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មបានដាក់កំហិតអន្តរាគមន៍របស់តុលាការនៅក្នុងដំណើរការមជ្ឈត្តការ។ ប៉ុន្តែមានការភាន់ច្រឡំមួយចំនួនទាក់ទងនឹងតួនាទីគ្រប់គ្រងរបស់តុលាការ។ មុខងារត្រួតពិនិត្យជាច្រើនរួមមាន៖ ការតែងតាំង ការជំទាស់ ការបញ្ចប់ ការខកខានក្នុងការបំពេញមុខងាររបស់មជ្ឈត្តករ និងយុត្តាធិការរបស់តុលាការត្រូវអនុវត្តដោយតុលាការ (តុលាការពាណិជ្ជកម្ម សាលាឧទ្ធរណ៍ តុលាការកំពូល

---

[29] ច្បាប់ស្ដីពីមជ្ឈការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ មាត្រា២៧។

[30] ដូចខាងលើ។

[31] វិធានស្ដីមជ្ឈការពាណិជ្ជកម្មរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១៤ វិធាន២.៣។

ឬ ម.ជ.ម.។[32] ចំណុចនេះហាក់ចង្អុលបង្ហាញថា គូភាគីអាចប្តឹងឧបាស្រ័យដោយផ្ទាល់ទៅស្ថាប័នណាមួយក្នុងចំណោមស្ថាប័នទាំងបួននេះ ដើម្បីស្នើសុំជំនួយផ្នែកគ្រប់គ្រង ហើយការប្តឹងឧបាស្រ័យមានតែពីរជម្រើសប៉ុណ្ណោះគឺតុលាការ ឬ ម.ជ.ម.។[33] ដោយសារខ្លឹមសារ ត្រង់ចំណុចនេះហាក់មានភាពស្រពិចស្រពិលអាចនាំឱ្យមានការភ័ន្តច្រឡំ ឬមានការអនុវត្តមិនស៊ីសង្វាក់គ្នា។ ចំពោះស្ថានភាពបច្ចុប្បន្ន ប្រការដែលល្អបំផុតក្នុងការស្វែងរកជំនួយត្រួតពិនិត្យពីតុលាការ គឺដាក់ញត្តិទៅសាលាឧទ្ធរណ៍ ប៉ុន្តែចំណុចនេះគួរតែលើកយកមកពិនិត្យឡើងវិញនៅពេលកែតម្រូវច្បាប់នេះនាពេលអនាគត។[34]

ផ្នែកនេះនឹងលើកឡើងពីដំណាក់កាលនីមួយៗនៃដំណើរការមជ្ឈត្តការពាណិជ្ជកម្មនៅកម្ពុជា និងបង្ហាញពីទិដ្ឋភាពសំខាន់ៗ នៃដំណាក់កាលទាំងនោះ។ ជាទូទៅ ដំណើរការមជ្ឈត្តការមានប្រាំមួយដំណាក់កាលរួមមាន[35]៖

១. ការផ្តួចផ្តើមមជ្ឈត្តការ

២. ការជ្រើសរើសវេទិការមជ្ឈត្តកម្ម

៣. នីតិវិធីមុនសវនាការ

៤. សវនាការមជ្ឈត្តការ

៥ . ការធ្វើសេចក្តីសម្រេច

៦. ការប្តឹងឧបាស្រ័យ និងការដាក់ឱ្យអនុវត្ត

## ២.១ ការផ្តួចផ្តើមដំណើរការមជ្ឈត្តការ

មជ្ឈត្តការអាចផ្តួចផ្តើមឡើងតាមវិធីបីយ៉ាងគឺ:

- ការស្នើឱ្យធ្វើមជ្ឈត្តការស្របតាមកិច្ចព្រមព្រៀងស្តីពីមជ្ឈត្តការដែលមានស្រាប់
- ការព្រមព្រៀងឱ្យមជ្ឈត្តការនៅពេលវិវាទកើតឡើង
- មជ្ឈត្តការដែលត្រូវអនុវត្តតាមបង្គាប់របស់តុលាការ។

---

[32] ច្បាប់ស្តីពីមជ្ឈការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ មាត្រា៦។

[33] ស៊ីវិន អ៊ែម អូស្ទីតមីឡឺរ៍ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា (ភ្នំពេញ ឆ្នាំ២០១០) ១៧៦។

[34] ដូចខាងលើ។

[35] ដូចខាងលើ។

ក្នុងចំណោមវិធីខាងលើនេះ ការស្នើឱ្យធ្វើមជ្ឍត្តការតាមកិច្ចព្រមព្រៀងមជ្ឍត្តការដែលមានស្រាប់ជាវិធីអនុវត្តទូទៅបំផុតសម្រាប់គូភាគី។

### ២.១.១ ការដាក់ពាក្យរបស់ភាគីបណ្តឹង

បើគូភាគីមានកិច្ចព្រមព្រៀងមជ្ឍត្តការជាមុនស្រាប់ ដែលជាទូទៅជាផ្នែកមួយនៃកិច្ចសន្យាគោល ភាគីម្ខាងត្រូវបង្ហាញដល់ភាគីម្ខាងទៀតនូវសំណើជាលាយលក្ខណ៍អក្សរ ហៅថា“សេចក្តីជូនដំណឹងអំពីមជ្ឍត្តកម្ម”។ ភាគីផ្តួចផ្តើមមជ្ឍត្តការ ហៅថា“ភាគីប្តឹងទាមទារ” ហើយភាគីដែលទទួលសំណើ ហៅថា“ភាគីឆ្លើយតប”។ ដើម្បីចាប់ផ្តើមមជ្ឍត្តការ ភាគីប្តឹងទាមទារត្រូវបញ្ជូនសេចក្តីជូនដំណឹងពីមជ្ឍត្តកម្មទៅអគ្គលេខាធិការដ្ឋាន ដែលត្រូវភ្ជាប់ព័ត៌មានដូចខាងក្រោម៖

- សេចក្តីថ្លែងដែលបញ្ជាក់ថាភាគីដាក់វិវាទឱ្យដោះស្រាយតាមមជ្ឍត្តកម្ម
- ឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ លេខទូរសារ និងអាសយដ្ឋានសារអេឡិចត្រូនិច ប្រសិនបើមានព័ត៌មានទាំងនេះរបស់គូភាគីវិវាទ និងរបស់អ្នកតំណាងរបស់គូភាគីវិវាទ
- សញ្ជាតិ ឬប្រសិនបើតម្រូវ និងមានព័ត៌មានអំពីអត្តសញ្ញាណរបស់ក្រុមហ៊ុនរបស់គូភាគីវិវាទ
- សេចក្តីយោងនៃខចែងស្តីពីមជ្ឍត្តកម្ម ឬកិច្ចសន្យាមជ្ឍត្តកម្មដោយឡែក ដែលយកមកប្រើ និងភ្ជាប់សំណៅចម្លងនៃខចែងស្តីពីមជ្ឍត្តកម្ម ឬកិច្ចសន្យាមជ្ឍត្តកម្មដោយឡែកនោះ
- សេចក្តីយោងនៃកិច្ចសន្យា ឬទំនាក់ទំនងផ្សេងៗដែលកើតចេញពី ឬដែលទាក់ទងនឹងវិវាទ និងភ្ជាប់សំណៅចម្លងនៃកិច្ចសន្យាទាំងនោះ
- សេចក្តីថ្លែងសង្ខេប ដែលពិព័ណនាអំពីលក្ខណៈ និងកាលៈទេសៈនៃវិវាទ ការទាមទារ ឬការសង្គ្រោះដែលទាមទារ និងប្រសិនបើអាច ភ្ជាប់តម្លៃបឋមនៃការទាមទារដែលភាគីប្តឹងទាមទារប្តឹងទាមទារមានបំណងដាក់ស្នើ
- ចំនួនមជ្ឍត្តករដែលបានព្រមព្រៀង ឬនៅក្នុងករណីដែលមិនមានការព្រមព្រៀងទេនោះ ចំនួនមជ្ឍត្តករដែលស្នើសុំ ដែលត្រូវមានចំនួន ១ (មួយ) រូប ឬ ៣ (បី) រូប និង
- សេចក្តីថ្លែង ឬសំណើបន្ថែមផ្សេងៗ ពាក់ព័ន្ធនឹងដំណើរការមជ្ឍត្តការ រួមបញ្ចូលទាំងច្បាប់ដែលត្រូវអនុវត្ត ភាសាសម្រាប់ដំណើរមជ្ឍត្តការ និងលក្ខណៈសម្បត្តិនិងសញ្ជាតិរបស់មជ្ឍត្តករដែលបានព្រមព្រៀង ឬដែលចង់បាន ប្រសិនបើមាន។

ដោយមិនគិតអំពីភាសាដែលត្រូវប្រើក្នុងដំណើរការមជ្ឈត្តការ ស្របតាមវិធាន១៨.១ (ភាសានៃដំណើរមជ្ឈត្តការ សេចក្តីជូនដំណឹងមជ្ឈត្តកម្ម ត្រូវធ្វើជាភាសាសម្រាប់មជ្ឈត្តកម្ម និងបកស្រាយជាភាសាខ្មែរ ឬភាសាអង់គ្លេស។[36]

សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មត្រូវមានភ្ជាប់មកជាមួយនូវការបង់ប្រាក់សម្រាប់កម្រៃសេវាចុះបញ្ជីដែលអាចជា មូលប្បទានបត្រ ឬការផ្ទេរចូលគណនីធនាគារកំណត់ណាមួយរបស់ ម.ជ.ម. (ចំពោះតារាងតម្លៃ សូមមើលឧបសម្ព័ន្ធ)។ ដំណើរការមជ្ឈត្តកម្មនឹងចាប់ផ្តើមនៅកាលបរិច្ឆេទ ដែលភាគីឆ្លើយតបបានទទួលការជូនដំណឹងពេញលេញពីអគ្គលេខាធិកាដ្ឋាន។[37] ករណីគូភាគីខកខានក្នុងការជ្រើសយកវិធានមជ្ឈត្តការក្នុងកិច្ចព្រមព្រៀងផ្សះផ្សា ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មចែងពីបញ្ញត្តិទូទៅមួយចំនួន ក្នុងនោះគូភាគីត្រូវដាក់លិខិតបញ្ជាក់ពីការប្តឹងទាមទារ ដែលត្រូវមានៈ

- អង្គហេតុដែលនាំឱ្យមានការទាមទារ
- ចំណុចវិវាទ
- ដំណោះស្រាយដែលខ្លួនចង់បាន។

## ២.១.២ ការដាក់ពាក្យរបស់ភាគីឆ្លើយតប

នៅពេលភាគីឆ្លើយតបទទួលបានការជូនដំណឹងពីការទទួលបានសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម ភាគីឆ្លើយតបត្រូវធ្វើសេចក្តីជូនដំណឹងអំពីការឆ្លើយតប ដើម្បីឆ្លើយតបទៅនឹងចំណុចដែលបានលើកឡើងនៅក្នុងបណ្តឹងទាមទារ ព្រមទាំងភ្ជាប់ឯកសារពាក់ព័ន្ធនឹងបណ្តឹងតបនោះ ហើយបញ្ជូនទៅអគ្គលេខាធិការដ្ឋានក្នុងរយៈពេល១៥ថ្ងៃ បន្ទាប់ពីទទួលបានការជូនដំណឹងអំពីការទទួលបានសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម ។[38]

[36] វិធានស្តីមជ្ឈការពាណិជ្ជកម្មរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១៤ វិធាន៧។

[37] វិធានស្តីមជ្ឈការពាណិជ្ជកម្មរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១៤ វិធាន៧.៧។

[38] វិធានស្តីមជ្ឈការពាណិជ្ជកម្មរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១៤ វិធាន៨។

## ២.២ ការជ្រើសរើស និងការជំទាស់នឹងវេទិកាមជ្ឈត្តកម្ម

### ២.២.១ ការជ្រើសរើសមជ្ឈត្តករ

ក្រោយពេលដាក់បណ្តឹងទាមទារបឋម ភាគីវិវាទត្រូវជ្រើសរើសវេទិកាមជ្ឈត្តកម្ម។ ភាគីវិវាទមានសេរីភាពក្នុងការកំណត់ចំនួនមជ្ឈត្តករ ប៉ុន្តែចំនួននោះត្រូវតែជាចំនួនដែលសេស[39] ហើយក្នុងករណីគ្មានការព្រមព្រៀងពីនីតិវិធី មជ្ឈត្តករត្រូវមានចំនួន៣នាក់។[40] ភាគីវិវាទមានសេរីភាពក្នុងការជ្រើសរើសយកវិធីសាស្ត្រណាមួយក្នុងការជ្រើសរើសមជ្ឈត្តការ។ ជាទូទៅ ពួកគេនឹងអនុវត្តតាមវិធីសាស្ត្រជ្រើសរើសរបស់មជ្ឈមណ្ឌលមជ្ឈត្តការដែលខ្លួនបានជ្រើសរើស។ ក្នុងករណីដែលពួកគេមិនបានជ្រើសរើសយកវិធីសាស្ត្រណាមួយទេ ភាគីនីមួយៗត្រូវតែងតាំងមជ្ឈត្តករម្នាក់ ហើយមជ្ឈត្តករទាំងពីនាក់ត្រូវតែងតាំងមជ្ឈត្តករទីបី។[41] បើការតែងតាំងមជ្ឈត្តការទីបីមិនបានធ្វើឡើងក្នុងរយៈពេល៣០ថ្ងៃ ក្រោយពេលតែងតាំងមជ្ឈត្តករទាំងពីរនាក់ដំបូង តុលាការកម្ពុជា ឬ ម.ជ.ម. ត្រូវតែងតាំងមជ្ឈត្តការទីបី ក្រោយមានសំណើរបស់ភាគីណាមួយក្នុងចំណោមភាគីទាំងពីរ។

### ២.២.២ ការជំទាស់នឹងមជ្ឈត្តករដែលត្រូវបានជ្រើសរើស

មុនពេលតែងតាំងមជ្ឈត្តករត្រូវបង្ហាញឱ្យដឹងនូវកាលៈទេសៈណាមួយដែលអាចបង្កការសង្ស័យដោយមូលហេតុសមរម្យទាក់ទងនឹងអព្យាក្រឹតភាព ឬឯករាជភាពរបស់ខ្លួន។[42] ចំណុចនេះអាចរាប់បញ្ចូលទំនាស់ផលប្រយោជន៍ជាមួយភាគីម្ខាង ឬច្រើនផងដែរ។

មជ្ឈត្តករអាចត្រូវបានជំទាស់ដោយមូលហេតុពីរយ៉ាង៖

- បើមានកាលៈដែលបង្កការសង្ស័យដោយមូលហេតុសមស្រប ពាក់ព័ន្ធនឹងអព្យាក្រឹតភាព ឬឯករាជ្យភាពរបស់គាត់
- បើគាត់គ្មានលក្ខខណសម្បត្តិដែលភាគីវិវាទបានព្រមព្រៀង។[43]

---

[39] ច្បាប់ស្តីពីមជ្ឈការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ មាត្រា១៩។

[40] ដូចខាងលើ និងវិធានស្តីមជ្ឈការពាណិជ្ជកម្មរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១៤ វិធាន១០។

[41] ដូចខាងលើ។

[42] ច្បាប់ស្តីពីមជ្ឈការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ មាត្រា២០។

[43] វិធានស្តីមជ្ឈការពាណិជ្ជកម្មរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ២០១៤ វិធាន១៣។

នៅពេលចុះកិច្ចសន្យា គូភាគីមានសេរីភាពក្នុងការយល់ព្រម ឬជំទាស់ចំពោះនីតិវិធីណាមួយរួមទាំងនីតិវិធីដែលមានក្នុងវិធានរបស់មជ្ឈមណ្ឌលមជ្ឈត្តការ។[44] បើគ្មានកិច្ចព្រមព្រៀងបែបនេះទេ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនឹងផ្តល់នីតិវិធីរបស់ខ្លួន។ ដំបូងភាគីដែលធ្វើការជំទាស់ត្រូវធ្វើបណ្តឹងជាលាយលក្ខណ៍អក្សរ ដែលបញ្ជាក់ពីមូលហេតុនៃការជំទាស់ក្នុងរយៈពេល១៥ថ្ងៃ ក្រោយពេលដែលបានដឹងពីកាលៈទេសៈដែលអាចនាំឱ្យមានបញ្ហា ឬការតែងតាំងដែលមានបញ្ហា។[45] បន្ទាប់មកវេទិការមជ្ឈត្តកម្មនឹងពិចារណា ហើយសម្រេចថាត្រូវយល់ព្រមតាមការជំទាស់ទេ។ បើយល់ព្រមមជ្ឈត្តករថ្មីម្នាក់ទៀតនឹងត្រូវតែងតាំងឡើង។ បើមិនយល់ព្រមទេ មជ្ឈត្តករដែលត្រូវប្តឹងទាស់នឹងនៅតែទទួលខុសត្រូវលើដំណើរការមជ្ឈត្តការនោះដដែល។ បន្ទាប់មក ភាគីប្តឹងទាស់អាចធ្វើការប្តឹងបន្តលើសេចក្តីសម្រេចរបស់វេទិការមជ្ឈត្តកម្មនោះ ក្នុងរយៈពេល៣០ថ្ងៃ ទៅកាន់តុលាការកម្ពុជា ឬ ម.ជ.ម.។[46]

ឧទាហរណ៍៖ ក្រុមហ៊ុន A និងក្រុមហ៊ុន B កំពុងតែជាប់ពាក់ព័ន្ធនៅក្នុងដំណើរការមជ្ឈត្តការមួយ។ ក្រុមហ៊ុន A បានតែងតាំងមជ្ឈត្តករម្នាក់ ដែលក្រុមហ៊ុន B ជឿថាមិនអព្យាក្រឹត ដោយសារគ្រួសាររបស់គាត់ធ្លាប់ធ្វើជំនួញជាមួយក្រុមហ៊ុន A។ យោងតាមវិធាននៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ក្រុមហ៊ុន B មានពេលវេលាចំនួន១៥ថ្ងៃ ចាប់ពីពេលខ្លួនបានដឹងពីការតែងតាំង ឬដឹងពីការធ្វើជំនួញរបស់មជ្ឈត្តករនោះជាមួយក្រុមហ៊ុន A ដើម្បីដាក់បណ្តឹងជំទាស់របស់ខ្លួន។ បណ្តឹងជំទាស់ត្រូវដាក់ទៅវេទិការមជ្ឈត្តកម្ម។ បើវេទិការមជ្ឈត្តកម្មចេញសេចក្តីសម្រេចលើកចោលការជំទាស់នោះ ពេលនោះក្រុមហ៊ុន A មានពេលវេលាចំនួន ៣០ថ្ងៃក្នុងការដាក់បណ្តឹងបន្តទៅតុលាការកម្ពុជា ឬទៅ ម.ជ.ម.។

### ២.២.៣ ការជំទាស់នឹងយុត្តាធិការរបស់វេទិការមជ្ឈត្តកម្ម

បើមានកិច្ចព្រមព្រៀងដែលមានសុពលភាព តុលាការកម្ពុជាត្រូវបញ្ជូនរឿងក្តីទៅមជ្ឈត្តការ។[47] ប៉ុន្តែភាគីអាចជំទាស់នឹងយុត្តាធិការរបស់មជ្ឈត្តកម្មក្នុងការជំនុំរឿងក្តីនោះមួយផ្នែក ឬទាំងអស់។

ឧទាហរណ៍៖ ភាគីម្ខាងអាចអះអាងថា ខ្លួនមិនដែលយល់ព្រមធ្វើមជ្ឈត្តកាលើវិវាទណាមួយឡើយ ហើយប្រហែលជាចង់បញ្ជូនបណ្តឹងតវ៉ានោះទៅតុលាការតាមច្បាប់។ ជាដំបូង ភាគីដែលអះអាងត្រូវធ្វើការទាមទារនេះជាមួយវេទិការមជ្ឈត្តកម្មសិន។ វេទិការមជ្ឈត្តកម្មមានអំណាចក្នុងការសម្រេចយុត្តាធិការរបស់ខ្លួន

---

[44] ស្ទីវិន អ៊ែម អូស្ទើតមីឡឺរ៍ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា (ភ្នំពេញ ឆ្នាំ២០១០) ១៧៦។

[45] ច្បាប់ស្តីពីមជ្ឈការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ មាត្រា២១។

[46] ដូចខាងលើ។

[47] ច្បាប់ស្តីពីមជ្ឈការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ មាត្រា៨។

រួមទាំងការជំទាស់នានា ដែលពាក់ព័ន្ធនឹងអត្ថិភាព សុពលភាព ឬវិសាលភាពអនុវត្តនៃកិច្ចសន្យាមជ្ឈត្តការ"។[48] ភាគីដែលជំទាស់ត្រូវលើកឡើងពីបញ្ហានេះក្នុងកំឡុងពេល ឬមុនកាលបរិច្ឆេទកំណត់សម្រាប់ការដាក់ពាក្យសេចក្ដីជូនដំណឹងអំពីការឆ្លើយតបរបស់ខ្លួន។ បន្ទាប់មកសេចក្ដីសម្រេចរបស់វេទិការមជ្ឈត្តកម្មពីបញ្ហាយុត្តាធិការអាចត្រូវប្ដឹងបន្តទៅតុលាការក្នុងរយៈពេល៣០ថ្ងៃ ក្រោយពេលវេទិការមជ្ឈត្តកម្មចេញសេចក្ដីសម្រេច។[49]

## ២.៣. ដំណើរការមុនសវនាការ

ក្រោយពេលមជ្ឈត្តករត្រូវបានជ្រើសរើសរួច ហើយយុត្តាធិការត្រូវបានកំណត់រួច ភាគីវិវាទមានបញ្ហាសំខាន់ៗជាច្រើនដែលត្រូវដោះស្រាយ ហើយជាទូទៅបញ្ហានេះ ត្រូវបញ្ចប់ក្នុងការប្រជុំពិភាក្សាមុនសវនាការដែលនីតិវិធី ទីតាំង ការបង្ហាញសក្ខីកម្ម និងបញ្ហាផ្សេងៗទៀតនឹងត្រូវសម្រេច ប្រសិនបើខចែងស្ដីពីមជ្ឈត្តការក្នុងកិច្ចសន្យាមិនបានចែង ឬចែងមិនច្បាស់លាស់ពីបញ្ហាទាំងនេះ។

### ២.៣.១ វិធានគ្រប់គ្រងនីតិវិធី

ភាគីវិវាទអាចកំណត់ពីវិធានគ្រប់គ្រងនីតិវិធីរបស់ខ្លួន។[50] មជ្ឈមណ្ឌលមជ្ឈត្តការជាច្រើនបានបង្កើតវិធាននីតិវិធីផ្សេងៗ ហើយជាទូទៅភាគីវិវាទតែងអនុម័តយកវិធានរបស់មជ្ឈមណ្ឌល ប៉ុន្តែពួកគេក៏អាចយល់ព្រមទទួលយកវិធានផ្ទាល់ដែលពួកគេបានជ្រើសរើស។ ករណីគ្មានវិធានស្ដីពីនីតិវិធីដែលគូភាគីបានព្រមព្រៀង វេទិការមជ្ឈត្តកម្មត្រូវដឹកនាំដំណើរការមជ្ឈត្តកម្មក្នុងរបៀបមួយដែលខ្លួនយល់ថាត្រឹមត្រូវ។[51]

### ២.៣.២ ទីកន្លែងមជ្ឈត្តការ

ទីកន្លែងមជ្ឈត្តការមានសារៈណាស់ ព្រោះច្បាប់ស្ដីពីមជ្ឈត្តការរបស់ប្រទេសម្ចាស់ផ្ទះនឹងមានភាពខុសគ្នា។[52] ភាគីវិវាទមានសេរីភាពក្នុងការកំណត់ទីកន្លែងធ្វើមជ្ឈត្តការនៅក្នុងកិច្ចព្រមព្រៀងរបស់ពួកគេ ឬនៅក្នុងលិខិតផ្សេងទៀត។[53] ក្នុងករណីដែលពួកគេមិនបានព្រមព្រៀងគ្នាលើរឿងនេះ ទីកន្លែងធ្វើមជ្ឈត្តការត្រូវកំណត់ដោយវេទិការមជ្ឈត្តកម្មដោយពិចារណាពីកាលៈទេសៈនៃរឿងក្ដីលើកលែងតែត្រូវបានព្រមព្រៀងគ្នាផ្សេងពីនោះដោយភាគីវិវាទវេទិការអាច ៖

---

[48] វិធានស្ដីមជ្ឈការពាណិជ្ជកម្មរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ២០១៤ វិធាន១៩.២។

[49] ច្បាប់ស្ដីពីមជ្ឈការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ មាត្រា២៤។

[50] ច្បាប់ស្ដីពីមជ្ឈការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ មាត្រា២៧។

[51] ដូចខាងលើ។

[52] ស្ទីវិន អ៊ែម អូស្ទើតមីឡឺរ៍ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា (ភ្នំពេញ ឆ្នាំ២០១០) ១៧៦។

[53] ច្បាប់ស្ដីពីមជ្ឈការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ មាត្រា២៨។

ប្រជុំនៅកន្លែងណាមួយដែលសមស្រប ដើម្បីពិគ្រោះយោបល់ក្នុងចំណោមសមាជិករបស់វេទិការ ស្តាប់សាក្សី អ្នកជំនាញការ ឬភាគីវិវាទ ឬធ្វើអធិការកិច្ច លើសម្ភារៈ កម្មសិទ្ធិ ឬឯកសារដទៃទៀត ។[54]

## ២.៣.៣ ភាសា

គូភាគីមានសេរីភាពក្នុងការយល់ព្រមលើភាសានៃដំណើរការមជ្ឈត្តការ ហើយបើគូភាគីមិនយល់ព្រមទេ វេទិការមជ្ឈត្តកម្មនឹងធ្វើការកំណត់ពីភាសានោះ។[55]

## ២.៣.៤ សន្ធានកម្ម

ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មចែងពីលទ្ធភាពក្នុងការធ្វើសន្ធានកម្ម ។ មាត្រា៣៨ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មចែងថា ៖

មុនពេលចាប់ផ្តើមដំណើរការមជ្ឈត្តការផ្លូវការ វេទិការមជ្ឈត្តកម្មត្រូវពិភាក្សាជាមួយភាគីវិវាទ ដើម្បីស្វែងរកមានលទ្ធភាពនៃការដោះស្រាយវិវាទ ដោយស្ម័គ្រចិត្តរបស់ភាគី ៖

១) បើភាគីវិវាទព្រមដោះស្រាយវិវាទដោយស្ម័គ្រចិត្ត វេទិការមជ្ឈត្តកម្មត្រូវជួយភាគីវិវាទ ទៅតាមបែបបទដែលសមស្រប.....[56]

មាត្រានេះអនុញ្ញាតឱ្យវេទិការមជ្ឈត្តកម្មស្វែងរកនូវដំណោះស្រាយតាមរយៈសន្ធានកម្ម ប៉ុន្តែលុះត្រាតែមានការស្នើពីភាគីទាំងពីរតែប៉ុណ្ណោះ។ ការធ្វើសន្ធានកម្មជាមុន បន្ទាប់មកទើបធ្វើមជ្ឈត្តការ ហៅថា"មជ្ឈត្តការសន្ធាន"។ បញ្ហាសំខាន់មួយដែលត្រូវពិចារណា គឺសន្ធានការីដែលអាចធ្វើជាមជ្ឈត្តករបានដែរឬទេ ក្នុងករណីដែលភាគីវិវាទបរាជ័យក្នុងការដោះស្រាយបញ្ហាទាំងអស់នៅក្នុងសន្ធានកម្ម។ គូភាគីភាគច្រើនមិនចង់ឱ្យសន្ធានការីធ្វើជាមជ្ឈត្តករនៅក្នុងវិវាទតែមួយទេដោយសារមូលហេតុពីរយ៉ាង។ ទីមួយ បើសន្ធានការីក្លាយជាមជ្ឈត្តករអាចនឹងមានភាពមិនស្មោះត្រង់នៅពេលដោះស្រាយវិវាទ។ ទីពីរ មជ្ឈត្តករអាចទទួលឥទ្ធិពលមិនសមស្របពីការប្រាស្រ័យទំនាក់ទំនង *តែម្ខាង* ដែលធ្វើឡើងដោយភាគីវិវាទ ដែលជាធម្មតាមជ្ឈត្តករនឹងមិនទទួលបានឡើយ បើខ្លួនមិនបានធ្វើជាសន្ធានការីពីមុនមកនោះ។ ដោយហេតុផលទាំងនេះហើយ គេតែងតែចង់ឱ្យមជ្ឈត្តករនៅក្នុងដំណើរការមជ្ឈត្តការសន្ធាន គឺជាមនុស្សផ្សេងគ្នាពីសន្ធានការី។ ដូច្នេះ គូភាគីត្រូវពិចារណាឱ្យបានមត់ចត់ពីខចែងស្តីពីមជ្ឈត្តការសន្ធានកម្ម។

---

[54] ដូចខាងលើ ។

[55] ច្បាប់ស្តីពីមជ្ឈការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ មាត្រា៣០។

[56] ច្បាប់ស្តីពីមជ្ឈការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ មាត្រា៣៨។

## ២.៣.៥ វិធានការបណ្តោះអាសន្ន

វិធានការបណ្តោះអាសន្នមានសារៈសំខាន់ណាស់។ នៅក្នុងស្ថានភាពមួយចំនួន ភស្តុតាងសំខាន់ៗ អាចទទួលការខូចខាត ឬមានការបំផ្លាញចោល ដរាបណាគ្មានការធានាសុវត្ថិភាពយ៉ាងត្រឹមត្រូវដោយតតិយជន ឬភាគីម្ខាងអាចនឹងត្រូវការឱ្យភាគីម្ខាងទៀតបញ្ឈប់សកម្មភាពមួយចំនួនភ្លាមៗ។ ស្រដៀងគ្នាទៅនឹងវិធានរបស់មជ្ឈមណ្ឌលមជ្ឈត្តការភាគច្រើនផ្សេងទៀតដែរ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មផ្តល់ដល់វេទិការមជ្ឈត្តកម្មនូវសិទ្ធិអំណាចក្នុងការចេញវិធានការបណ្តោះអាសន្នទាំងនេះ។ វេទិការមជ្ឈត្តកម្មក៏អាចស្នើរឱ្យភាគីម្ខាងផ្តល់ប្រាក់ធានាសមស្របទាក់ទងនឹងវិធានទាំងនេះផងដែរ។

ភាគីនីមួយៗក៏អាចស្វែងរកការចេញដីកាសម្រេចជាបណ្តោះអាសន្នពីតុលាការកម្ពុជាផងដែរ។ យោងតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ត្រង់ចំណុចនេះ នៅមុនពេល ឬក្នុងពេលកំពុងដំណើរការមជ្ឈត្តកម្ម ការធ្វើសំណូមពររបស់ភាគីវិវាទមួយទៅតុលាការឱ្យផ្តល់វិធានការបណ្តោះអាសន្ន ដើម្បីការពារ និងការផ្តល់នូវវិធាននោះដោយតុលាការ ពុំមានវិសមិតភាពជាមួយកិច្ចព្រមព្រៀងផ្សះផ្សាឡើយ។ ខចែងនេះអាចជាបញ្ហាដ៏មានសក្តានុពល សម្រាប់ភាគីបរទេសដែលមានបំណងចង់គេចពីប្រព័ន្ធតុលាការក្នុងស្រុក។ វិធីម្យ៉ាងក្នុងការគេចពីប្រព័ន្ធតុលាការនេះ គឺត្រូវដាក់លក្ខខណ្ឌសមស្របទៅក្នុងខចែងស្តីពីមជ្ឈត្តការ ដែលរារាំងភាគីណាមួយមិនឱ្យប្តឹងទៅតុលាការដើម្បីស្នើសុំវិធានការបណ្តោះអាសន្ន។

## ២.៣.៦ ការបង្ហាញព័ត៌មានឱ្យដឹង ឬការជូនដំណឹងគ្នាទៅវិញទៅមក

ប្រព័ន្ធតុលាការមួយចំនួន ដូចជានៅសហរដ្ឋអាមេរិកជាដើម ការបង្ហាញព័ត៌មានមានលក្ខណៈទូលាយ និងជាលក្ខខណ្ឌតម្រូវចំពោះគូភាគីមុនសវនាការ។ ព័ត៌មានទាំងនោះរួមមាន៖ ឯកសារ កស្សិណរបស់សាក្សី និងភាគីនានាជាដើម។ ក្នុងប្រព័ន្ធច្បាប់កុំមិនឡ លក្ខខណ្ឌតម្រូវនេះហៅថា *"ការផ្លាស់ប្តូរព័ត៌មាន"*។ ប៉ុន្តែនៅប្រព័ន្ធច្បាប់ស៊ីវិល ការតម្រូវនេះមានលក្ខណៈរឹតត្បឹតជាង។ ចំពោះវិធានមជ្ឈត្តការភាគច្រើនយល់ថា លក្ខខណ្ឌតម្រូវឱ្យបង្ហាញព័ត៌មានមុនសវនាការមានលក្ខណៈរឹតត្បឹត។ គូភាគីអាចកំណត់ពីកម្រិតនៃការបង្ហាញព័ត៌មានមុនសវនាការតាមការចង់បានរបស់ខ្លួន។

តាមរយៈច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម គូភាគីត្រូវបង្ហាញព័ត៌មានដល់គ្នាទៅវិញទៅមក៖ *"រាល់សេចក្តីថ្លែង ឯកសារ ឬព័ត៌មានដទៃទៀត"* ដែលបានដាក់ជូនវេទិការមជ្ឈត្តកម្ម។ មុនពេលសវនាការមជ្ឈត្តការ គូភាគីមានឱកាសត្រួតពិនិត្យ *"សម្ភារៈ ទំនិញ ទ្រព្យសម្បត្តិ ឬឯកសារផ្សេង"*។ គូភាគីមានសេរីភាពក្នុងការអនុម័តវិធានផ្សេងៗទៀត ស្តីពីការផ្លាស់ប្តូរព័ត៌មានដែលមានលក្ខណៈទូលាយជាងនេះ។ ការព្រមព្រៀងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ក្នុងករណីគូភាគីត្រូវបង្ហាញវេទិការមជ្ឈត្តកម្មពីចំណុចអ្វីដែលត្រូវបង្ហាញចេញ

ហើយខកខានមិនបានបង្ហាញចេញ។ វិធានស្តីពីការផ្លាស់ប្តូរព័ត៌មានដែលកាន់តែមានលក្ខណៈទូលាយ នឹងនាំឱ្យមានការពន្យារពេលនៃដំណើរការមជ្ឈត្តការ និងចំណាយថ្លៃមេធាវីកាន់តែខ្ពស់។ ផ្ទុយទៅវិញ ការផ្លាស់ប្តូរព័ត៌មានដែលមានលក្ខណៈរឹតត្បឹត និងមិនគ្រប់គ្រាន់អាចនាំឱ្យមានការយឺតយ៉ាវក្នុងពេលសវនាការ នៅពេលភាគីម្ខាងស្នើសុំពេលវេលាបន្ថែមដើម្បីឆ្លើយតបនឹងបញ្ហា និងភស្តុតាងដែលមិនបានព្រៀងទុកជាមុន។

### ២.៣.៧ អ្នកជំនាញ

មជ្ឈត្តករមានសិទ្ធិតែងតាំងអ្នកជំនាញ លើកលែងតែគូភាគីយល់ព្រមផ្សេងពីនេះ។ គូភាគីត្រូវប្រាប់អ្នកជំនាញពីព័ត៌មានពាក់ព័ន្ធទាំងអស់។ មជ្ឈត្តករមានសិទ្ធិត្រួតពិនិត្យអ្នកជំនាញនៅពេលសវនាការ ក្រោយពេលអ្នកជំនាញដាក់សេចក្តីសន្និដ្ឋានជូនទៅវេទិការមជ្ឈត្តកម្ម។[57]

## ២.៤. សវនាការមជ្ឈត្តការ

ដំណើរការមជ្ឈត្តការតម្រូវឱ្យមានសវនាការមួយដែលស្រដៀងគ្នានឹងដំណើរការជំនុំជំម្រះក្នុងតុលាការប្រព័ន្ធច្បាប់កុំមិនទ្បូ ដែលតម្រូវឱ្យគូភាគីធ្វើសេចក្តីថ្លែងបើក ដោយបញ្ជាក់ពីអង្គហេតុ និងអង្គច្បាប់។ បន្ទាប់មកភាគីប្តឹងធ្វើការបង្ហាញសាក្សី និងឯកសារជាភស្តុតាងរបស់ខ្លួន។ សាក្សីត្រូវធ្វើការស្បថស្បែរដូចនឹងដំណើរការកាត់ក្តីនៅតុលាការដែរ។ វេទិការមជ្ឈត្តកម្មនឹងសម្រេចថាតើសាក្សីដែលមិនមែនជាភាគីវិវាទអាចមានវត្តមាននៅក្នុងពេលធ្វើមជ្ឈត្តការ ឬទេ។ ភាគីប្តឹង ឬមេធាវីរបស់ខ្លួននឹងសួរសំនួរដល់សាក្សីដែលមានវត្តមានដោយផ្ទាល់នៅចំពោះមុខវេទិការមជ្ឈត្តកម្ម។ ពេលខ្លះវេទិការមជ្ឈត្តកម្មនឹងសួរសំនួរបន្ថែមស្រដៀងនឹងចៅក្រមដែរ។ ភាគីឆ្លើយតបក៏មានសិទ្ធិលើកជាសំនួរសួរទៅសាក្សីរបស់ភាគីប្តឹងដែរ។

ក្រោយពេលភាគីប្តឹងបានបង្ហាញនូវភស្តុតាងទាំងអស់របស់ខ្លួនរួច ភាគីឆ្លើយតបនឹងមានឱកាសបង្ហាញសាក្សី និងឯកសារជាភស្តុតាងរបស់ខ្លួនវិញម្តង។ ជាថ្មីម្តងទៀត វេទិការមជ្ឈត្តកម្ម និងភាគីប្តឹងក៏អាចសួរសំនួរទៅសាក្សីទាំងនោះបានដែរ។ បន្ទាប់មក គូភាគីនឹងផ្លាស់វេនគ្នាធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ ហើយបន្ទាប់ពីនោះមក វេទិការមជ្ឈត្តកម្ម នឹងពិភាក្សាដើម្បីសម្រេចរឿងក្តីនេះ។ សវនាការមជ្ឈត្តការមានលក្ខណៈមិនផ្លូវការដូចដំណើរការកាត់ក្តីនៅតុលាការឡើយ។បញ្ហានីតិវិធី ឬបញ្ហាភស្តុតាងមានភាពទន់ភ្លន់ជាងនៅតុលាការ។ បើគូភាគីយល់ព្រម ពួកគេមិនចាំបាច់ធ្វើសវនាការផ្ទាល់មាត់នោះទេ។គូភាគីអាចជ្រើសរើសធ្វើត្រឹមតែបង្ហាញភស្តុតាងជាឯកសារ និងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដាក់ជូនវេទិការមជ្ឈត្តកម្មដើម្បីពិចារណាក៏បាន។ ប៉ុន្តែបើ

[57] ច្បាប់ស្តីពីមជ្ឈការផ្នែកពាណិជ្ជកម្ម រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ មាត្រា៣៤។

ភាគីណាមួយចង់ឱ្យមានសវនាការផ្ទាល់មាត់ នោះសវនាការផ្ទាល់មាត់ត្រូវតែធ្វើឡើង។ ច្បាប់ស្តីពីមជ្ឈត្តកម្មផ្នែកពាណិជ្ជកម្មក៏តម្រូវឱ្យគូភាគីទទួលបានការជូនដំណឹងគ្រប់គ្រាន់ពីសវនាការដែរ។

## ២.៥. ការធ្វើសេចក្តីសម្រេច

ក្រោយពេលសវនាការមជ្ឈត្តការបានបញ្ចប់សព្វគ្រប់ វេទិការមជ្ឈត្តកម្មត្រូវបង្វែរការយកចិត្តដាក់ទៅលើការធ្វើសេចក្តីសម្រេច។ យោងតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ភាគីវិវាទអាចជ្រើសរើសច្បាប់ណាមួយនៃយុត្តាធិការមកអនុវត្តក៏បាន។ ការព្រមព្រៀងនេះ ហៅថា"បទបញ្ញត្តិពីជម្រើសនៃច្បាប់នៅក្នុងកិច្ចព្រមព្រៀងរបស់ភាគីវិវាទ"។ ករណីដែលគ្មានបញ្ញត្តិស្តីពីជម្រើសនៃច្បាប់ទេ វេទិការមជ្ឈត្តកម្មមានសេរីភាពក្នុងការជ្រើសរើសច្បាប់ណាមួយដែលខ្លួនយល់ថាសមស្របមកអនុវត្ត។

❖ តួនាទីវេទិការមជ្ឈត្តកម្ម

គូភាគីអាចផ្តល់សិទ្ធិឱ្យវេទិការមជ្ឈត្តកម្មធ្វើជាអ្នកជួយសម្រុះសម្រួល (ចេញសេចក្តីសម្រេចដោយផ្អែកលើអ្វីដែលត្រឹមត្រូវ) ជាជាងដើរតួនាទីជាចៅក្រម (ចេញសេចក្តីសម្រេចដោយផ្អែកលើច្បាប់)។ តាមវិធីស្រុះស្រួល វេទិការមជ្ឈត្តកម្មចាំបាច់ចេញសេចក្តីសម្រេច ដោយផ្អែកលើគោលការណ៍សមធម៌ និងយុត្តិធម៌ជាជាងគោលការណ៍ច្បាប់។ ការធ្វើដូច្នេះអាចនាំឱ្យសេចក្តីសម្រេចដែលមើលទៅដូចជាការស្រុះស្រួលគ្នា ដែលក្នុងនោះភាគីនីមួយៗទទួលបានអ្វីម្យ៉ាង។ ការធ្វើដូច្នេះកនាំឱ្យមានការចេញសេចក្តីសម្រេចដោយផ្អែកលើស្មារតីយុត្តិធម៌របស់មជ្ឈត្តករម្នាក់ៗ ពោលគឺសុទ្ធតែផ្អែកលើច្បាប់។ ទោះបីជាការធ្វើដូច្នេះអាចជាមធ្យោបាយ ដ៏ល្អមួយសម្រាប់គូភាគីដែលមានអារម្មណ៍ថា ខ្លួនបានធ្វើខុសក៏ដោយនឹងបង្កើតឱ្យមានភាពមិនច្បាស់លាស់ចំពោះលទ្ធផល។ ជម្រើសនេះត្រូវតែមានការយល់ព្រមពីគូភាគីទាំង ពុំនោះវេទិការមជ្ឈត្តកម្មធ្វើសេចក្តីសម្រេចដោយផ្អែកលើច្បាប់ជាធរមាន។

❖ បទដ្ឋានពាណិជ្ជកម្ម

ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មចែងថា ចំពោះគ្រប់ករណីទាំងអស់ វេទិការមជ្ឈត្តកម្មត្រូវយកចិត្តទុកដាក់ដល់ទម្លាប់ពាណិជ្ជកម្ម ដែលអនុវត្តបានចំពោះមុខជំនួញ។ មានន័យថា បញ្ញត្តិនេះនឹងអនុវត្តទោះបីជាច្បាប់ដែលគូភាគីជ្រើសរើស មិនបានចែងពីទម្លាប់ផ្នែកពាណិជ្ជកម្មក៏ដោយ។

❖ សេចក្តីសម្រេចដោយសម្លេងភាគច្រើន

បើវេទិការមានមជ្ឈត្តករច្រើនជាងម្នាក់ នោះសេចក្តីសម្រេចរបស់វេទិការអាចធ្វើឡើងដោយសម្លេងភាគច្រើនដោយប្រៀបនៃសមាជិក។[58]

## ❖ វិធានគ្របដណ្តប់ក្នុងករណីខកខាន

ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មមិនមានផ្តល់នូវវិធានក្នុងករណីដែលភាគីម្ខាងខកខានមិនបានគោរព តាមវិធានទាំងនោះឡើយ។ បើភាគីប្តឹងខកខានមិនបានបញ្ជូនបណ្តឹងទាមទាររបស់ខ្លួន ឱ្យស្របតាមវិធាននេះ វេទិការមជ្ឈត្តកម្មត្រូវបញ្ចប់ដំណើរការនោះ។ ផ្ទុយមកវិញ បើភាគីខកខានមិនបានឆ្លើយតបបញ្ជូនពាក្យដោះសាររបស់ខ្លួនទេ វេទិការត្រូវបន្តដំណើរការមជ្ឈត្តការនោះ និងមិនត្រូវបកស្រាយថាការខកខាននោះជាការសារភាពឡើយ។

បើភាគីទាំងពីរខកខានមិនបានបង្ហាញខ្លួននៅក្នុងសវនាការ ឬខកខានមិនបានផ្តល់ភស្តុតាងជាឯកសារនានានោះ វេទិការ*អាច* បន្តដំណើរការកាត់ក្តី និងធ្វើមជ្ឈត្តវិនិច្ឆ័យពីភស្តុតាងដែលមាននោះបាន។ ការប្រើប្រាស់ពាក្យថា *អាច*នៅក្នុងប្រយោគនេះ ជំនួសឱ្យពាក្យថា *ត្រូវ*នោះបញ្ជាក់ថា នៅក្នុងស្ថានភាពបែបនេះ វេទិការអាចជ្រើសរើសមិនបន្តដំណើរការកាត់ក្តីតទៅទៀតបាន។ គួរកត់សម្គាល់ថា មជ្ឈមណ្ឌលមជ្ឈត្តការនានាមានវិធានក្នុងករណីខកខាន ដែលគេអាចជ្រើសរើសជំនួសឱ្យវិធានទាំងនេះរបស់ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់កម្ពុជា។

## ❖ ទម្រង់នៃមជ្ឈត្តវិនិច្ឆ័យ

ដើម្បីចងភ្ជាប់កាតព្វកិច្ច និងដើម្បីឱ្យអាចអនុវត្តបានតាមរយៈតុលាការ មជ្ឈត្តវិនិច្ឆ័យត្រូវ ៖

- ធ្វើឡើងជាលាយលក្ខណ៍អក្សរ និងចុះហត្ថលេខាដោយសម្លេងភាគច្រើននៃមជ្ឈត្តករ។
- បញ្ជាក់ពីហេតុផលដែលចេញមជ្ឈត្តវិនិច្ឆ័យយោងតាម។
- បែងចែកក្នុងចំណោមភាគីវិវាទនូវថ្លៃចំណាយលើមជ្ឈត្តការតាមដែលវេទិការមជ្ឈត្តកម្មយល់ថាសមស្រប លើកលែងតែភាគីវិវាទមានការព្រមព្រៀងគ្នាផ្សេងពីនោះ។ ថ្លៃឈ្នួលមេធាវីដែលសមស្របរបស់ភាគីឈ្នះក្តី ក៏អាចត្រូវបានបង្គាប់ឱ្យទៅភាគីម្ខាងទៀតដែរ។
- បញ្ជាក់ពីកាលបរិច្ឆេទ និងទីកន្លែងធ្វើមជ្ឈត្តការ។
- ភាគីនីមួយៗត្រូវទទួលបានមជ្ឈត្តវិនិច្ឆ័យដែលមានចុះហត្ថលេខាមួយច្បាប់។[59]

---

[58] ច្បាប់ស្តីពីមជ្ឈការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ មាត្រា៣៧។

[59] ច្បាប់ស្តីពីមជ្ឈការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ មាត្រា៣៩។

រាល់ការស្រុះស្រួលដែលសម្រេចបានក្រោមមាត្រា ៣៨ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ត្រូវគោរពតាមលក្ខខណ្ឌតម្រូវដូចគ្នានេះ ហើយត្រូវបញ្ជាក់ផងដែរថា វាគឺជាមជ្ឈត្តវិនិច្ឆ័យ ដើម្បីធ្វើឱ្យមានអានុភាព និងប្រសិទ្ធភាពជាសាលក្រម។ នៅពេលវេទិការមជ្ឈត្តកម្មចេញសេចក្តីសម្រេច អគ្គលេខាធិការត្រូវបោះត្រា ម.ជ.ម. ហើយបញ្ជូនទៅគូភាគី ហើយប្រសិនបើភាគីណាមួយចង់ស្នើសុំកែប្រែ ការបំភ្លឺលម្អិត និងបកស្រាយសេចក្តីសម្រេច ឬសេចក្តីសម្រេចបន្ថែម ភាគីនោះត្រូវស្នើសុំទៅអគ្គលេខាធិកាដ្ឋានក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីទទួលបានសេចក្តីសម្រេច។[60]

## ២.៦. ការប្តឹងឧបាស្រ័យនឹងការដាក់ឱ្យអនុវត្ត

### ២.៦.១ ការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ

មជ្ឈត្តវិនិច្ឆ័យអាចត្រូវប្តឹងជំទាស់តែក្នុងកាលៈទេសៈរឹតត្បឹតបំផុត។ ការអនុញ្ញាតឱ្យភាគីម្ខាងធ្វើការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យដោយងាយស្រួល នឹងធ្វើឱ្យបាត់គុណប្រយោជន៍របស់មជ្ឈត្តការ ពោលលទ្ធភាពក្នុងការផ្តល់នូវដំណោះស្រាយវិវាទយ៉ាងឆាប់រហ័ស មានប្រសិទ្ធភាព និងប្រកបដោយលក្ខណៈវិជ្ជាជីវៈ។ គូភាគី នឹងបាត់បង់ទំនុកចិត្តក្នុងការជ្រើសយកមជ្ឈត្តការមកដោះស្រាយវិវាទ បើមជ្ឈត្តវិនិច្ឆ័យអាចត្រូវបានប្តឹងជំទាស់យ៉ាងងាយស្រួលនៅតុលាការនោះ។ ដូច្នេះច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មបានចែងពីមូលហេតុតិចតួចប៉ុណ្ណោះក្នុងការលុបចោល(ធ្វើមោឃកម្ម) មជ្ឈត្តវិនិច្ឆ័យណាមួយ។ ក្នុងចំណោមមូលហេតុដែលត្រូវបានរៀបរាប់ គ្មានមូលហេតុណាមួយដែលទាក់ទងនឹងតម្រូវការពិនិត្យមើលឡើងវិញពីលក្ខណៈសម្បត្តិនៃភស្តុតាង និងសេចក្តីសម្រេចឡើយ។ តុលាការកម្ពុជាអាចលុបចោលនូវមជ្ឈត្តវិនិច្ឆ័យណាមួយបាន បើៈ

- ភាគីមួយនៃកិច្ចព្រមព្រៀងផ្សះផ្សា...អសមត្ថភាពនៅពេលចុះកិច្ចព្រមព្រៀងនោះ ឬមួយកិច្ចព្រមព្រៀងនោះគ្មានសុពលភាព យោងតាមច្បាប់ដែលគ្រប់គ្រងវា ឬ
- ភាគីម្ខាងមិនបានទទួលការជូនដំណឹងត្រឹមត្រូវពីការតែងតាំងមជ្ឈត្តករ ឬពីដំណើរការមជ្ឈត្តការនោះ ឬមិនអាចបង្ហាញពីអង្គហេតុរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ឬ
- មជ្ឈត្តវិនិច្ឆ័យដែលទាក់ទិននឹងវិវាទនោះ ពុំគោរពតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងផ្សះផ្សា ឬ
- ការបង្កើតវេទិការមជ្ឈត្តកម្ម ឬដំណើរការមជ្ឈត្តការ ពុំស្របតាមកិច្ចព្រមព្រៀង ឬ
- កម្មវត្ថុនៃវិវាទមិនអាចដោះស្រាយបានដោយមជ្ឈត្តការឡើយ យោងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬ

[60] វិធានស្តីមជ្ឈការពាណិជ្ជកម្មរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ២០១៤ វិធាន៣៨។

- មជ្ឈត្តវិនិច្ឆ័យនោះនឹងផ្ទុយពីនយោបាយសាធារណៈរបស់ព្រះរាជាណាចក្រកម្ពុជា។[61]

មូលហេតុចំនួនបួនដំបូងត្រូវលើកឡើង និងបញ្ជាក់ដោយភាគី។ តុលាការបន្ទុកទទួលពិនិត្យឡើងវិញអាចពិចារណាពីមូលហេតុចំនួនពីរចុងក្រោយ (តាមឆន្ទានុសិទ្ធិរបស់ខ្លួន)។ គួរបញ្ជាក់ថា ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មចែងថា តុលាការកម្ពុជាអាចលុបចោលមជ្ឈត្តវិនិច្ឆ័យ ផ្អែកលើមូលហេតុទាំងនេះ ប៉ុន្តែមិន*តម្រូវ* ថាត្រូវតែដូច្នោះទេ។ គូភាគីដែលស្វែងរកការលុបចោលមជ្ឈត្តវិនិច្ឆ័យ ត្រូវដាក់ពាក្យសុំទៅសាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេល៣០ថ្ងៃ ក្រោយទទួលបានលិខិតជូនដំណឹងពីមជ្ឈត្តវិនិច្ឆ័យនោះ។ បណ្តឹងសាទុក្ខពីសាលាឧទ្ធរណ៍ចេញសាលដីការួច។[62] នៅក្នុងកាលៈទេសៈសមស្រប តុលាការកម្ពុជាអាចផ្អាកដំណើរការកាត់ក្តីនៅតុលាការសិន ដើម្បីអនុញ្ញាតឱ្យវេទិការមជ្ឈត្តកម្មបន្តដំណើរការកាត់ក្តី ឬចាត់វិធានការលុបបំបាត់មូលហេតុនៃការលុបចោលមជ្ឈត្តវិនិច្ឆ័យនោះ ដើម្បីឱ្យវេទិការមជ្ឈត្តកម្មអាចបញ្ចប់ដំណើរការស្របតាមច្បាប់។

## ២.៦.២ ការទទួលស្គាល់និងការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ

ក្រោយពេលចេញមជ្ឈត្តវិនិច្ឆ័យរួច ភាគីឈ្នះក្តីត្រូវតែស្នើសុំអនុវត្តមជ្ឈត្តវិនិច្ឆ័យ បើភាគីចាញ់ក្តីខកខានមិនបានគោរពតាមមជ្ឈត្តវិនិច្ឆ័យនោះ។ អាស្រ័យហេតុនេះ គូភាគីត្រូវផ្អែកលើប្រព័ន្ធតុលាការដើម្បីអនុវត្តមជ្ឈត្តវិនិច្ឆ័យនោះ តាមរយៈការស្នើសុំដីកាសម្រេចអនុវត្តនៅសាលាឧទ្ធរណ៍។[63] យោងតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នៅពេលដែលមជ្ឈត្តវិនិច្ឆ័យចូលជាធរមាន ត្រូវដាក់ឱ្យអនុវត្តដូចគ្នានឹងសាលក្រមតុលាការដែរ។

ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មចែងថា ៖

> មជ្ឈត្តវិនិច្ឆ័យ ទោះបីជាបានធ្វើនៅប្រទេសណាក៏ដោយ ក៏ត្រូវបានទទួលស្គាល់ថាជាកាតព្វកិច្ច ហើយបន្ទាប់ពីបានពាក្យសុំជាលាយលក្ខណ៍អក្សរទៅតុលាការមានសមត្ថកិច្ចរួច ត្រូវបានអនុវត្ត.....[64]

ពាក់ព័ន្ធនឹងបញ្ហានីតិវិធី ភាគីដែលស្វែងរកការទទួលស្គាល់ និងដាក់ឱ្យអនុវត្ត ត្រូវផ្តល់ដល់តុលាការនូវសំណៅដើម ឬសំណៅចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវនៃមជ្ឈត្តវិនិច្ឆ័យ និងកិច្ចព្រមព្រៀងមជ្ឈត្តការ ព្រម

[61] ច្បាប់ស្តីពីមជ្ឈការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ មាត្រា៤៦។

[62] ច្បាប់ស្តីពីមជ្ឈការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ មាត្រា៤៤។

[63] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា៣៥៣ និងច្បាប់ស្តីពីការយល់ព្រម និងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិចែងអំពីការទទួលស្គាល់និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០១ មាត្រា ៦។

[64] ច្បាប់ស្តីពីមជ្ឈការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ មាត្រា៤៥។

ទាំងសំណៅបកប្រែជាភាសាខ្មែរដែលមានការបញ្ជាក់ត្រឹមត្រូវ ក្នុងករណីដែលសំណៅដើមមិនមែនសរសេរជាភាសាខ្មែរ។ ក្រោយពេលដាក់ជូនត្រឹមត្រូវរួច តុលាការត្រូវទទួលស្គាល់ និងអនុវត្តមជ្ឈត្តិវិនិច្ឆ័យប្រៀបដូចជាមជ្ឈត្តិវិនិច្ឆ័យនោះគឺជាសាលក្រមស្ថាពរ និងអាចអនុវត្តបានដូច្នោះដែរ។

តុលាការអាចបដិសេធក្នុងការអនុវត្តមជ្ឈត្តិវិនិច្ឆ័យនោះបាន ដោយយោងតាមកាលៈទេសៈរឹតត្បិតមួយចំនួនដូចខាងក្រោម ៖

- ភាគីម្ខាងនៃកិច្ចព្រមព្រៀងផ្សះផ្សា អសមត្ថភាពនៅពេលចុះកិច្ចព្រមព្រៀងនេះ ឬកិច្ចព្រមព្រៀងនេះគ្មានសុពលភាពយោងតាមច្បាប់គ្រប់គ្រង ឬ
- ភាគីម្ខាងពុំបានព័ត៌មានត្រឹមត្រូវពីការតែងតាំងមជ្ឈត្តករ ឬពីដំណើរការមជ្ឈត្តកម្ម ឬពុំអាចបង្ហាញពីករណីរបស់ខ្លួនបានដោយប្រសិទ្ធភាព ឬ
- មជ្ឈត្តិវិនិច្ឆ័យដែលទាក់ទងនឹងវិវាទនោះ ពុំគោរពតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងផ្សះផ្សា ឬ
- ការបង្កើតផទិការមជ្ឈត្តកម្ម ឬដំណើរការមជ្ឈត្តការពុំស្របតាមកិច្ចព្រមព្រៀងរបស់ភាគីវិវាទ ឬ
- មជ្ឈត្តិវិនិច្ឆ័យពុំបានក្លាយជាកាតព្វកិច្ចនៅឡើយ សម្រាប់ភាគីវិវាទ ឬ
- កម្មវត្ថុនៃវិវាទនោះពុំអាចដោះស្រាយតាមមជ្ឈត្តការឡើយ យោងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬ
- ការទទួលស្គាល់មជ្ឈត្តិវិនិច្ឆ័យ អាចផ្ទុយនឹងនយោបាយសាធារណៈរបស់ព្រះរាជាណាចក្រកម្ពុជា។[65]

ចំនុចទាំងប្រាំដំបូងអាចត្រូវបានលើកឡើងនិងបញ្ជាក់ដោយភាគីម្ខាង រីឯចំនុចពីរចុងក្រោយអាចលើកឡើងដោយតុលាការខ្លួនឯង។ មូលហេតុក្នុងការបដិសេធការទទួលស្គាល់ ឬការអនុវត្តមជ្ឈត្តិវិនិច្ឆ័យទាំងនេះដូចគ្នាស្ទើរតែទាំងស្រុងនឹងមូលហេតុសម្រាប់ការលុបចោលមជ្ឈត្តិវិនិច្ឆ័យ។ មូលហេតុបន្ថែមដើម្បីបដិសេធការអនុវត្តគឺ មជ្ឈត្តិវិនិច្ឆ័យមិនទាន់ភ្ជាប់កាតព្វកិច្ចលើគូភាគីក្នុងប្រទេសដែលមជ្ឈត្តិវិនិច្ឆ័យនោះត្រូវបានធ្វើឡើង។ ខ្លឹមសារនេះ ស្រដៀងគ្នានឹងបញ្ញត្តិដែលចែងថា តុលាការកម្ពុជា *អាច* បដិសេធការអនុវត្តមជ្ឈត្តិវិនិច្ឆ័យផ្អែកតាមមូលហេតុទាំងនេះ ប៉ុន្តែមិន*តម្រូវ*ឱ្យត្រូវតែដូច្នេះឡើយ។ តុលាការអាចផ្អាកដំណើរការដាក់ឱ្យអនុវត្ត ដោយរង់ចាំលទ្ធផលនៃវិធានការរបស់តុលាការ ដោយភាគីម្ខាងកំពុងតែស្វែងរកការលុបចោលមជ្ឈត្តិវិនិច្ឆ័យ។

---

[65] ច្បាប់ស្តីពីមជ្ឈការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ មាត្រា៤៤។

### ២.៦.៣ ការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យអន្តរជាតិ

ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មមិនត្រឹមតែចែងពីការអនុវត្តមជ្ឈត្តវិនិច្ឆ័យជាតិប៉ុណ្ណោះទេ ថែមទាំងចែងពីការអនុវត្តមជ្ឈត្តវិនិច្ឆ័យអន្តរជាតិផងដែរ។ ច្បាប់ស្តីពីមជ្ឈត្តការពាណិជ្ជកម្មបានចែងថា មជ្ឈត្តការត្រូវបានចាត់ទុកថាជាអន្តរជាតិបើ ៖

(១) ភាគីវិវាទ និងកិច្ចព្រមព្រៀងផ្សះផ្សាមានទីកន្លែងធ្វើពាណិជ្ជកម្មនៅក្នុងប្រទេសផ្សេងពីគ្នាក្នុងពេលសម្រេចកិច្ចព្រមព្រៀងនោះ ឬ

(២) ទីកន្លែងមួយក្នុងចំណោមទៅកន្លែងខាងក្រោម ស្ថិតនៅក្រៅប្រទេសធ្វើពាណិជ្ជកម្មរបស់ភាគីវិវាទ ៖

-ទីកន្លែងធ្វើមជ្ឈត្តការ ៖ បើបានកំណត់នៅក្នុង ឬបានយោងក្នុងកិច្ចព្រមព្រៀងផ្សះផ្សា

-ទីកន្លែងដែលកាតព្វកិច្ចសំខាន់នៃទំនាក់ទំនងពាណិជ្ជកម្មបានប្រព្រឹត្តទៅ ឬទីកន្លែងដែលជិតជាងគេពាក់ព័ន្ធនឹងវិវាទ ឬ

(៣) ភាគីវិវាទបានព្រមព្រៀងជាក់លាក់ថារឿងនៃកិច្ចព្រមព្រៀងផ្សះផ្សាទាក់ទងនឹងប្រទេសលើសពីមួយ។[66]

តាមរយៈការសង្ខេបកថាខណ្ឌនេះ ៖

- ❖ បើភាគីមួយមានទីកន្លែងប្រកបពាណិជ្ជកម្មលើសពីមួយ នោះទីកន្លែងដែលមានទំនាក់ទំនងជិតស្និទ្ធជាងគេបំផុតនឹងកិច្ចព្រមព្រៀងផ្សះផ្សា ជាទីកន្លែងពាណិជ្ជកម្ម
- ❖ បើភាគីមួយគ្មានទីកន្លែងប្រកបពាណិជ្ជកម្មទេ នោះទីលំនៅអចិន្ត្រៃយ៍របស់ភាគីជាទីកន្លែងពាណិជ្ជកម្ម។

ចំពោះមជ្ឈត្តការអន្តរជាតិ ការអនុម័តច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនាំឱ្យប្រទេសកម្ពុជាបំពេញតាមលក្ខខណ្ឌតម្រូវនៃអនុសញ្ញាក្រុងញូវយ៉កស្តីពីការទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យបរទេស ឆ្នាំ១៩៥៨ (អនុសញ្ញាក្រុងញូវយ៉ក) បានទាំងស្រុង។ អនុសញ្ញាក្រុងញូវយ៉ក ផ្តល់នូវក្របខណ្ឌអន្តរជាតិដ៏ចម្បងសម្រាប់ការទទួលស្គាល់ និងការអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេស និងមជ្ឈត្តវិនិច្ឆ័យអន្តរជាតិ។

ឧទាហរណ៍៖ វិវាទរវាងក្រុមហ៊ុនចិន និងក្រុមហ៊ុនជប៉ុនដែលបានធ្វើមជ្ឈត្តការនៅទីក្រុងបាងកកអាចសុំអនុវត្តប្រឆាំងនឹងភាគីនីមួយៗនៅកម្ពុជាបើភាគីនីមួយៗមានទ្រព្យសម្បត្តិនៅកម្ពុជា។ អនុសញ្ញានេះ និងរបបអនុវត្តន៍ជាអន្តរជាតិជាមូលហេតុមួយក្នុងចំណោមមូលហេតុដែលក្រុមហ៊ុនអន្តរជាតិចូលចិត្តធ្វើមជ្ឈត្តការ ព្រោះ

[66] ច្បាប់ស្តីពីមជ្ឈការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ មាត្រា២ ។

ក្នុងករណីមានវិវាទនឹងមានការធានាថាមជ្ឈត្តវិនិច្ឆ័យនោះអាចអនុវត្តបានស្មើរតែនៅគ្រប់ទីកន្លែងនៅក្នុងពិភពលោក។ ដោយសារប្រទេសកម្ពុជាគឺជាផ្នែកមួយនៃប្រព័ន្ធអនុវត្តន៍នេះ ក្រុមហ៊ុនអន្តរជាតិកាន់តែមានបំណងចង់ធ្វើការវិនិយោគនៅក្នុងប្រទេសកម្ពុជាថែមទៀត។

យោងតាមអនុសញ្ញាក្រុងញូវយ៉ក ប្រទេសកម្ពុជាត្រូវតែអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេស ប៉ុន្តែពុំមានវិធីសាស្ត្រអនុវត្តច្បាស់លាស់ទេ រហូតទាល់តែច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មត្រូវបានអនុម័ត។ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មចែងថា ៖

"មជ្ឈត្តវិនិច្ឆ័យទោះជាបានធ្វើនៅក្នុងប្រទេសណាក៏ដោយត្រូវបានគេទទួលស្គាល់ថាជាកាតព្វកិច្ច....ត្រូវបានអនុវត្ត...."។[67]លើកលែងតែមានមូលហេតុមួយចំនួនតូចប៉ុណ្ណោះសម្រាប់បដិសេធ តុលាការកម្ពុជាត្រូវអនុវត្តមជ្ឈត្តវិនិច្ឆ័យនោះ។[68]

ដោយសារតែច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មបានចូលជាធរមាន ទើបប្រទេសកម្ពុជាមានក្របខណ្ឌផ្លូវច្បាប់ច្បាស់លាស់មួយសម្រាប់ដំណើរការអនុវត្តមជ្ឈត្តវិនិច្ឆ័យអន្តរជាតិ។ ជាលទ្ធផល នៅឆ្នាំ២០១៤ តុលាការប្រទេសកម្ពុជាបានទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យអន្តរជាតិ ដែលបានសម្រេចដោយវេទិកា មជ្ឈត្តការរបស់កូរ៉េ និងបានអនុវត្តមជ្ឈត្តវិនិច្ឆ័យនោះនៅប្រទេសកម្ពុជាជាលើកដំបូង។[69] ក្នុងការអនុវត្តមជ្ឈត្តវិនិច្ឆ័យអន្តរជាតិនៅកម្ពុជា ភាគីដែលឈ្នះត្រូវស្នើសុំដីកាសម្រេចអនុវត្តពីសាលាឧទ្ធរណ៍ដោយគោរពទៅតាមនីតិវិធីដូចគ្នាទៅនឹងការស្នើរសុំអនុវត្តមជ្ឈត្តវិនិច្ឆ័យជាតិដែរ។[70]

---

67 ច្បាប់ស្តីពីមជ្ឈការផ្នែកពាណិជ្ជកម្ម រាជធានីភ្នំពេញ ថ្ងៃទី ០៦ មីនា ២០០៩, មាត្រា៤៥។

68 ដូចខាងលើ។

69 https://www.mekongresearch.org/blog/2017/9/14/commercial-arbitration-and-alternative- dispute-resolution-in-the-kingdom

70 ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣៥៣(៦) និង https://www.dfdl.com/resources/legal-and-tax-updates/investment-guide-cambodia-2/។

# សេចក្តីសន្និដ្ឋាន
# និង
# អនុសាសន៍

# សេចក្តីសន្និដ្ឋាន

តាមរយៈលទ្ធផលនៃការស្រាវជ្រាវប្រធានបទ "មជ្ឈត្តការពាណិជ្ជកម្មនៅកម្ពុជា" រួចមកបានបង្ហាញឱ្យឃើញថា ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជាយន្តការមួយដ៏ល្អសម្រាប់ពាណិជ្ជករ។ ការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការ មានរយៈពេលខ្លីជាង ឆាប់រហ័ស រក្សាការសម្ងាត់ និងចំណាយតិចជាងនីតិវិធីតាមប្រព័ន្ធតុលាការ ។ ដូច្នេះក្នុងការដោះស្រាយវិវាទពាណិជ្ជកម្ម ភាគីវិវាទគួរតែធ្វើការជ្រើសរើសមជ្ឈត្តការមកធ្វើការដោះស្រាយវិវាទរបស់ខ្លួន ហើយនៅក្រោយពេលដែលចេញសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ ភាគីវិវាទអាចយកសេចក្តីសម្រេចនេះទៅអនុវត្តជាអន្តរជាតិ ។

ជាការពិតណាស់ ក្នុងការប្រកបរបរអាជីវកម្ម អាជីវករតែងតែថ្លឹងថ្លែង និងសិក្សាយ៉ាងជាក់លាក់រវាងហានិភ័យ និងផលចំណេញ។ ប៉ុន្តែ នៅពេលដែលបរិយាកាសអាជីវកម្មគ្មានស្ថេរភាព ឬមិនអាចព្យាករទុកមុនបាន នោះវានឹងបង្កការលំបាកក្នុងការថ្លឹងថ្លែងពីហានិភ័យ និងផលចំណេញ។ ហេតុដូច្នេះហើយ តម្រូវការនៃប្រព័ន្ធច្បាប់ល្អ និងច្បាស់លាស់សម្រាប់ការធ្វើអាជីកម្ម ពិតជាចាំបាច់ណាស់ក្នុងការជម្រុញការវិនិយោគ និងកំណើនសេដ្ឋកិច្ច។ ប្រទេសជាច្រើនដែលមានប្រព័ន្ធច្បាប់ខ្សោយ និងមានយន្តការដោះស្រាយវិវាទពាណិជ្ជកម្មស្មុគស្មាញ មានកំណើនសេដ្ឋកិច្ចទាបជាងប្រទេសដែលមានប្រព័ន្ធច្បាប់ល្អប្រសើរ។ កត្តានេះបណ្តាលមកពីអាជីវករស្ទាក់ស្ទើរក្នុងការចុះកិច្ចសន្យា ឬធ្វើពាណិជ្ជកម្មផ្សេងៗ នៅពេលដែលគេគ្មានទំនុកចិត្តថា ប្រព័ន្ធច្បាប់នឹងអនុវត្តកិច្ចសន្យារបស់គេបាន ដែលនាំឱ្យខូចខាតដល់សកម្មភាពវិនិយោគ។

ការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការនឹងផ្តល់ទំនុកចិត្តដល់ពាណិជ្ជករ និងវិនិយោគិនក្នុងការទទួលបានសេចក្តីសម្រេចដែលមានអនុភាពអនុវត្តជាអន្តរជាតិ ជាពិសេសការគោរពគោលការណ៍សេរីភាពឆ្លុះបញ្ចាំងពីសុចរិតភាព និងតម្លាភាពនៃនីតិវិធីតាំងពីពេលចាប់ផ្តើមដំណាក់កាលដំបូង ដោយផ្សារភ្ជាប់នឹងគុណភាព និងប្រសិទ្ធភាពនៃការដោះស្រាយទំនាស់។

ជារួមមក ការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការមានគុណសម្បត្តិដូចជា ឆាប់រហ័ស រក្សាការសម្ងាត់ និងការចំណាយតិចជាងនីតិវិធីតាមប្រព័ន្ធតុលាការ ហើយនៅក្រោយពេលដែលចេញនូវសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ ភាគីវិវាទអាចយកសេចក្តីសម្រេចនេះទៅអនុវត្តជាអន្តរជាតិ។ ដូច្នេះក្នុងការដោះស្រាយវិវាទពាណិជ្ជកម្ម ភាគីវិវាទគួរតែជ្រើសយកមជ្ឈត្តការមកដោះស្រាយវិវាទរបស់ខ្លួន។

# អនុសាសន៍

ក្នុងអំឡុងពេលនៃការស្រាវជ្រាវនេះ នាងខ្ញុំបានសង្កេតឃើញចំណុចគួរឱ្យកត់សម្គាល់មួយចំនួនដែរ។ ចំពោះប្រទេសកម្ពុជា ថ្វីបើសេដ្ឋកិច្ចមានលក្ខណៈវិជ្ជមាន និងមានកំណើនខ្លាំងជាច្រើនឆ្នាំកន្លងមក បើប្រព័ន្ធច្បាប់កាន់តែល្អប្រសើរជាងនេះនឹងធ្វើឱ្យប្រទេសកម្ពុជាមានកំណើនវិនិយោគច្រើនជាងនេះទៀត ហើយប្រហែលជាអាចជំរុញឱ្យមានកំណើនសេដ្ឋកិច្ចរឹតតែខ្ពស់ជាងពេលបច្ចុប្បន្ន។ បើក្រលេកមើលទៅអនាគត ការកែលម្អប្រព័ន្ធដោះស្រាយវិវាទពាណិជ្ជកម្មនៅកម្ពុជា មានសារៈសំខាន់ណាស់សម្រាប់ប្រទេសកម្ពុជាក្នុងការថែរក្សាកំណើនដ៏ខ្ពស់នេះក្នុងរយៈពេលវែង។ ដូច្នេះការកែលម្អប្រព័ន្ធមជ្ឈត្តការពាណិជ្ជកម្មនៅកម្ពុជានឹងជម្រុញឱ្យអាជីវករ និងវិនិយោគិនងាកមកដោះស្រាយវិវាទតាមយន្តការក្រៅប្រព័ន្ធតុលាការ។

ដើម្បីចូលរួមចំណែកក្នុងការជួយវិស័យមជ្ឈត្តការនៅកម្ពុជាឱ្យកាន់តែរីកចម្រើន នាងខ្ញុំសូមជូនជាមតិយោបល់ខ្លះៗដូចជា៖

- ❖ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មគួរតែជម្រុញឱ្យមានការបង្កើនវគ្គបណ្តុះបណ្តាលបន្ថែមដល់មជ្ឈត្តករ
- ❖ សិក្សាបទពិសោធន៍ និងគំរូរបស់បណ្តាប្រទេសដែលមានភាពជឿនលឿនលើវិស័យមជ្ឈត្តការដូចជាប្រទេសបារាំង សិង្ហបុរី ហុងកុង សហរដ្ឋអាមេរិក និងអង់គ្លេសជាដើម។
- ❖ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មត្រូវគ្រប់គ្រងតម្លៃនៃដំណើរការមជ្ឈត្តការឱ្យសមរម្យ ដើម្បីឱ្យពាណិជ្ជករមានលទ្ធភាពទទួលបានការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការ ។
- ❖ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មត្រូវព្យាយាមបង្កើនគុណភាព តាមរយៈការផ្តល់ដំណោះស្រាយឆាប់រហ័ស និងមានប្រសិទ្ធភាពដល់គូភាគីដើម្បីទាក់ទាញឱ្យមានពាណិជ្ជករ និងវិនិយោគិន។
- ❖ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មត្រូវរក្សា និងធានាចំពោះគូភាគីនូវយុត្តិធម៌ ភាពមិនលម្អៀង និងឯករាជ្យភាពរបស់មជ្ឈមណ្ឌលក៏ដូចជាមជ្ឈត្តករដើម្បីផ្តល់ទំនុកចិត្តដល់ពាណិជ្ជករ និងវិនិយោគិន។
- ❖ របបគត្តយុត្តិទាក់ទិននឹងវិស័យមជ្ឈត្តការពាណិជ្ជកម្ម ហាក់មានភាពខ្វះចន្លោះ ហើយបទប្បញ្ញត្តិមួយចំនួនហាក់មានភាពស្រពិចស្រពិល អាស្រ័យហេតុនេះ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មគួរតែចេញរបបគត្តយុត្តិបន្ថែមដើម្បីគ្រប់គ្រងចំណុចខ្វះខាតនៃរបបគត្តយុត្តិទាក់ទិននឹងវិស័យមជ្ឈត្តការពាណិជ្ជកម្មបច្ចុប្បន្ន។

# ឯកសារយោង

# ឯកសារយោង

- **លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ**


១.សន្ធិសញ្ញាទីក្រុងញ៉ូវយកស្តីពី ការទទួលស្គាល់ និងការអនុវត្តសេចក្តីសម្រេចមជ្ឈត្តការបរទេស ឆ្នាំ១៩៥៨។

២.ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

៣.ច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩។

៤.ច្បាប់ស្តី ពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣។

៥.ច្បាប់ស្តីពី ការយល់ព្រម និងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាត់ចែងអំពីការទទួលស្គាល់ និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០១។

៦.អនុក្រឹត្យស្តី ពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលមជ្ឈត្តការពាណិជ្ជកម្មកម្ពុជា ឆ្នាំ២០០៩។

៧.វិធានមជ្ឈត្តការពាណិជ្ជកម្មរបស់មជ្ឈមណ្ឌលមជ្ឈត្តការពាណិជ្ជកម្មកម្ពុជា ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៤។

៨.ក្រមសីលធម៌សម្រាប់មជ្ឈត្តករដែលបានចុះបញ្ជី ឬប្រតិបត្តិក្រោមវិធានរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៥។


- **សៀវភៅនិងអត្ថបទពាក់ព័ន្ធ**


១. សៀវភៅស្តីពី មជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិ រៀបរៀងដោយ ម៉ាហ្គារ៉េត ម៉ូសេស បោះពុម្ពឆ្នាំ២០០៨។

២. សៀវភៅស្តីពី ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ប្រទេសកម្ពុជា រៀបរៀងដោយ លោក ស៊ីរិន អ៊ែម អូស្ទើរមីឡឺរ៍ បោះពុម្ពលើកទី២ ឆ្នាំ២០១០។

៣. អត្ថបទស្តីពី ការដោះស្រាយវិវាទពាណិជ្ជកម្មនៅកម្ពុជានិងផែនការបង្កើតមជ្ឈមណ្ឌលនៃមជ្ឈត្តការ ដែលមានចែងក្នុងព្រឹត្តប័ត្រស្តីពី បញ្ហាអាជីវកម្ម ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៧។

៤. អត្ថបទស្តីពី ចំណុចវិវាទដែលអាចសម្រេចបានដោយវេទិការមជ្ឈត្តកម្មពាណិជ្ជកម្មនៅកម្ពុជា រៀបរៀងដោយ លោកមេធាវី គឹម សាន។

៥. អត្ថបទស្តីពី ការតែងតាំងមជ្ឈត្តករផ្នែកពាណិជ្ជកម្ម រៀបរៀងដោយ លោកមេធាវី គឹម សាន។

៦. បញ្ជីសមាជិក ម.ជ.ម. រៀបរៀងដោយ មជ្ឈមណ្ឌលមជ្ឈត្តការពាណិជ្ជកម្មកម្ពុជា បោះពុម្ពឆ្នាំ២០១៩។

- **គេហទំព័រពាក់ព័ន្ធ**


១.http://arbitrationblog.kluwerarbitration.com/2015/06/10/cambodias-arbitration-centre-sets-off-on-its-first-flight/?doing_wp_cron=1598032610.8003931045532226562500 (ចូលទស្សនាថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០)។

២.https://www.b2b-cambodia.com/articles/resolving-business-disputes-in-the-kingdom/ (ចូលទស្សនាថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០)។

៣.https://www.bun-associates.com/introductory-guide-commercial-arbitration-in-cambodia/ (ចូលទស្សនាថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០)។

៤.https://www.dfdl.com/resources/legal-and-tax-updates/investment-guide-cambodia-2/ (ចូលទស្សនាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០)។

៥.https://www.khmertimeskh.com/724106/resolving-commercial-disputes-without-going-to-law-qa/ (ចូលទស្សនាថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០)។

៦.https://www.mekongresearch.org/blog/2017/9/14/commercial-arbitration-and-alternative-dispute-resolution-in-the-kingdom (ចូលទស្សនាថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២០)។

៧.https://www.phnompenhpost.com/national/enforcing-foreign-judgments-cambodia (ចូលទស្សនាថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២០)

# ឧបសម្ព័ន្ធ

# មាតិកាឧបសម្ព័ន្ធ

| | |
|---|---|
| **ឧបសម្ព័ន្ធទី១៖** | ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩។ |
| **ឧបសម្ព័ន្ធទី២៖** | ច្បាប់ស្តីពី ការយល់ព្រម និងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាត់ចែងអំពីការទទួលស្គាល់ និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០១។ |
| **ឧបសម្ព័ន្ធទី៣៖** | ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។ |
| **ឧបសម្ព័ន្ធទី៤៖** | អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលមជ្ឈត្តការពាណិជ្ជកម្មកម្ពុជា។ |
| **ឧបសម្ព័ន្ធទី៥៖** | វិធានមជ្ឈត្តការពាណិជ្ជកម្មរបស់មជ្ឈមណ្ឌលមជ្ឈត្តការពាណិជ្ជកម្មកម្ពុជា ឆ្នាំ២០១៤។ |
| **ឧបសម្ព័ន្ធទី៦៖** | ឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងមជ្ឈមណ្ឌលមជ្ឈត្តការពាណិជ្ជកម្មកម្ពុជា ( គំរូវិញ្ញាបនប័ត្រប្រកបវិជ្ជាជីវៈជាមជ្ឈត្តករ គំរូតម្លៃនៃដំណើរការមជ្ឈត្តការ គំរូខចែងពីមជ្ឈត្តការពាណិជ្ជកម្ម។ល។ ) |